MEKONG RIVER COMMISSION
MRC
FOR SUSTAINABLE DEVELOPMENT

# របាយការណ៍ស្តីពីស្ថានភាពនៃអាងទន្លេ ឆ្នាំ ២០១០

## សេចក្តីសង្ខេប










គណៈកម្មការទន្លេមេគង្គ ឆ្នាំ ២០១០
*របាយការណ៍ស្តីពីស្ថានភាពនៃអាងទន្លេ : ឆ្នាំ ២០១០,*
*សេចក្តីសង្ខេប*
គណៈកម្មការទន្លេមេគង្គ, ប្រទេសឡាវ

ISBN 978-993-2080-58-8

©គណៈកម្មការទន្លេមេគង្គ

PO Box 6101,
Unit 18 Ban Sithane Neua, Sikhottabong District,
Vientiane 01000, Lao PDR
email: mrcs@mrcmekong.org
www.mrcmekong.org

Design by Silkworm Books • www.silkwormbooks.com
Print and bound in Thailand by O. S. Printing House, Bangkok

ឯកសារនេះមានជាភាសាអង់គ្លេស ខ្មែរ ឡាវ ថៃ
និងវៀតណាម។

សំរាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង: mrcs@mrcmekong.org
របាយការណ៍ស្តីពីស្ថានភាពនៃអាងទន្លេ និងសេចក្តីសង្ខេប
នេះ អាចទាញយកមកប្រើប្រាស់បាន នៅលើគេហទំព័រ
របស់គណៈកម្មការទន្លេមេគង្គ www.mrcmekong.org





# អារម្ភកថា

មនុស្សប្រហែល ៦០ លាននាក់ កំពុងរស់នៅក្នុងអាងទន្លេមេគង្គក្រោម ខណៈពេលដែលកំណើនសេដ្ឋកិច្ចបានធ្វើឲ្យមានការ កែលម្អយ៉ាងច្រើនដល់កម្រិតជីវភាពរស់នៅរបស់ប្រជាជន នារយៈពេលប៉ុន្មានឆ្នាំមកនេះ មនុស្សជាច្រើននៅក្នុងអាងទន្លេនេះនៅតែរស់នៅក្នុងភាពក្រីក្រ។ ជីវភាព និងសន្តិសុខស្បៀងរបស់ប្រជាជន ភាគច្រើន មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងទន្លេមេគង្គ និងធនធានទាំងឡាយដែលទន្លេមេគង្គបានជួយ។

គណៈកម្មការទន្លេមេគង្គ (Mekong River Commission) ត្រូវបានលេចរូបរាងឡើងតាំងពីឆ្នាំ ១៩៩៥ ហើយតួនាទីរបស់វា គឺដើម្បីជួយដល់បណ្តារដ្ឋាភិបាលនៃអាងទន្លេមេគង្គក្រោម (ប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម) ក្នុងការគ្រប់គ្រងទឹក និងធនធានពាក់ព័ន្ធនានា ដែលមាននៅក្នុងអាងទន្លេនេះឲ្យមាននិរន្តរភាព និងជួយប្រើប្រាស់ធនធានទាំងនេះ ដើម្បីលើកកំពស់ប្រជាជនឲ្យចេញផុតពីភាពក្រីក្រ។ វាមានសារៈសំខាន់ណាស់ដែលក្រុមអ្នកធ្វើការសម្រេចចិត្តមានព័ត៌មានច្បាស់លាស់ និងទាន់ហេតុការណ៍នៅក្នុងវិស័យនានាទាក់ទងនឹងទឹក និងមានការយល់ដឹងពីផលប៉ះពាល់នៃការអភិវឌ្ឍវិស័យទាំងនេះ ទៅលើសេដ្ឋកិច្ច បរិស្ថាន និងប្រជាជន។ ដើម្បីគាំទ្រគោលបំណងទាំងនេះ គណៈកម្មការទន្លេមេគង្គបានផ្សព្វផ្សាយរបាយការណ៍ឆ្នាំ ២០១០ ស្តីពី*ស្ថានភាពនៃអាងទន្លេ* ។ សេចក្តីសង្ខេបនេះបានផ្តោតទៅលើលទ្ធផលមួយចំនួនក្នុងចំណោមលទ្ធផលសំខាន់ៗដែលមានក្នុងរបាយការណ៍។

របាយការណ៍លើកទី ២ នេះស្តីពី *ស្ថានភាពនៃអាងទន្លេ* បានពិពណ៌នាពីធនធានទឹក និងធនធានដែលពាក់ព័ន្ធនឹងទឹកនៃអាងទន្លេមេគង្គក្រោម។ របាយការណ៍នេះបានធ្វើការសង្ខបបញ្ហាមួយចំនួនក្នុងចំណោមបញ្ហាប្រឈមនានាក្នុងការអភិវឌ្ឍសម្រាប់អាងទន្លេមេគង្គក្រោម ក្នុងនោះរួមមានការអភិវឌ្ឍថាមពលវារីអគ្គិសនី ការផ្លាស់ប្តូរការប្រើប្រាស់ដី និងការប្រែប្រួលអាកាសធាតុ។ បញ្ហាទាំងនេះនឹងត្រូវបានត្រួតពិនិត្យ និងលើកឡើងម្តងទៀត តាមលំដាប់លំដោយ នៅក្នុងរបាយការណ៍ស្តីពី*ស្ថានភាពនៃអាងទន្លេ* ។

ការយល់ដឹងពីស្ថានភាពធនធានទឹកក្នុងអាងទន្លេនេះ បានផ្តល់ជាទស្សនៈវិស័យធំទូលាយ ទៅលើភាពងាយរងគ្រោះខ្លាំងរបស់ប្រជាជនរស់នៅក្នុងតំបន់នេះ និងផ្តល់ព័ត៌មានស្តីពីគោលបំណងកាត់បន្ថយភាពក្រីក្ររបស់រដ្ឋាភិបាលនៃប្រទេសជាសមាជិករបស់គណៈកម្មការទន្លេមេគង្គ ដែលប្រទេសទាំងអស់នេះសុទ្ធតែបានបញ្ជាក់ពីបំណងប្រាថ្នា ក្នុងការបំពេញបន្ថែមទៀតទៅលើផលប្រយោជន៍ជាច្រើនដែលមានស្រាប់របស់ធនធានធម្មជាតិ ដែលទន្លេមេគង្គបានផ្តល់ឲ្យដោយការបញ្ចូលអាងទន្លេមេគង្គទៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសខ្លួន។

គណៈកម្មការទន្លេមេគង្គ និងប្រទេសជាសមាជិកទាំងបួនកំពុងរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេមេគង្គ ដោយផ្អែកលើការរៀបចំធនធានទឹកចម្រុះមួយ។ យុទ្ធសាស្ត្រនេះនឹងបញ្ចប់នៅក្នុងឆ្នាំ ២០១០។ ដូចជាអាងដទៃទៀតដែរ ជម្រើសដែលត្រូវបានផ្តល់ព័ត៌មានត្រូវតែធ្វើឡើង ហើយការអភិវឌ្ឍមួយចំនួននៃការអភិវឌ្ឍដែលបានស្នើសុំ ជាពិសេសគម្រោងសុំសាងសង់ថាមពលវារីអគ្គិសនីតាមដងទន្លេមេគង្គ គឺស្ថិតក្នុងភាពចម្រូងចម្រាស់។ របាយការណ៍នេះជាការរួមចំណែកយ៉ាងសំខាន់សម្រាប់ការពិភាក្សាដែលកំពុងកើតមាន ដែលត្រូវធ្វើឡើងក្នុងចំណោមអ្នកពាក់ព័ន្ធនានានៅក្នុងបណ្តាប្រទេសនៃអាងទន្លេមេគង្គ និងជួយបំពេញបន្ថែមដល់ការវិភាគផ្សេងៗទៀត ដែលត្រូវធ្វើឡើងដោយគណៈកម្មការទន្លេមេគង្គទៅលើឱកាស និងភាពប្រថុយប្រថានជាប់ពាក់ព័ន្ធនឹងផែនការអភិវឌ្ឍន៍ផ្សេងៗនាពេលអនាគត។

របាយការណ៍នេះ បានធ្វើការសង្ខេបបញ្ហាប្រឈមសំខាន់ៗមួយចំនួន ដែលទាមទារឲ្យមានការសហការបន្ថែមទៀតនៅក្នុងការត្រួតពិនិត្យ ការស្រាវជ្រាវ និងការគ្រប់គ្រង នារយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ។ បញ្ហាប្រឈមជាច្រើនបានក្លាយជាផ្នែកសំខាន់នៃការងាររបស់គណៈកម្មការទន្លេមេគង្គ ហើយខ្ញុំជឿជាក់ថា ការផ្តោតការយកចិត្តទុកដាក់ទៅលើបញ្ហាទាំងនេះនៅក្នុងរបាយការណ៍ នឹងជួយឲ្យមានការយល់ដឹងបន្ថែមទៀតរបស់សាធារណជន ទៅលើបញ្ហាទាំងនេះ។

ជីវភាពរបស់ប្រជាជនរាប់លាននាក់ ពឹងផ្អែកទៅលើការគ្រប់គ្រងដោយប្រុងប្រយ័ត្ននៃអាងទន្លេនេះនៅក្នុងលក្ខណៈបើកចំហ និងមានតម្លាភាព។ ជាទីបញ្ចប់ ខ្ញុំជឿជាក់ថា របាយការណ៍ឆ្នាំ ២០១០ ស្តីពី *ស្ថានភាពនៃអាងទន្លេ* នឹងអាចជាឯកសារយោងដ៏មានតម្លៃសម្រាប់ការធ្វើផែនការយុទ្ធសាស្ត្រនៅក្នុងតំបន់ទន្លេមេគង្គ នារយៈពេលច្រើនឆ្នាំខាងមុខនេះ និងផ្តល់ជាមូលដ្ឋានគ្រឹះនៃគោលនយោបាយទឹក និងបរិស្ថានដែលផ្អែកលើចំណេះដឹង។



Jeremy Bird

មន្ត្រីប្រតិបត្តិថ្នាក់ខ្ពស់

លេខាធិការដ្ឋាននៃគណៈកម្មការទន្លេមេគង្គ

# សេចក្តីសង្ខេប

របាយការណ៍ស្តីពីស្ថានភាពនៃអាងទន្លេរបស់គណៈកម្មការទន្លេមេគង្គ មានគោលបំណងផ្តល់ជាទិដ្ឋភាពរួមមួយនៃស្ថានភាពរបស់អាងទន្លេមេគង្គផ្នែកខាងក្រោម ដែលក្នុងនោះរួមមានស្ថានភាពប្រជាជន និងជីវភាពរបស់ពួកគេ បរិស្ថាន និងសេដ្ឋកិច្ច។ ចាប់តាំងពីរបាយការណ៍លើកទី១ស្តីពីស្ថានភាពនៃអាងទន្លេត្រូវបានផ្សព្វផ្សាយ នៅឆ្នាំ ២០០៣ មក ការស្រាវជ្រាវ និងការត្រួតពិនិត្យ បានផ្តល់ជាព័ត៌មានដែលជួយក្នុងការបង្កើតទិដ្ឋភាពនៃស្ថានភាព និងនិន្នាការនៃសូចនាករសំខាន់ៗមួយចំនួន។ ដោយមានជំនួយពីព័ត៌មាននេះ របាយការណ៍នេះក៏ផ្តោតទៅលើបញ្ហាប្រឈមមួយចំនួនសម្រាប់បណ្តាប្រទេសក្នុងអាងទន្លេមេគង្គក្រោមផងដែរ។

នគរូបនីយកម្ម គឺជានិន្នាការមួយនៅក្នុងបណ្តាប្រទេសទាំងបួនក្នុងអាងទន្លេមេគង្គក្រោម ដោយសារតែប្រជាជនបានធ្វើចំណាកស្រុកពីតំបន់ជនបទដើម្បីស្វែងរកឱកាសរស់នៅក្នុងតំបន់ទីក្រុងដែលកំពុងតែរីកធំឡើងៗ។ ខណៈពេលដែលប្រជាជនភាគច្រើននៃប្រជាជន ៦០ លាននាក់ ដែលរស់នៅក្នុងអាងទន្លេនេះ នៅតែបន្តរស់នៅក្នុងតំបន់ជនបទ អត្រាកំណើនប្រជាជនជនបទនឹងមានការធ្លាក់ចុះនៅទសវត្សក្រោយ។ តួលេខបានបង្ហាញថាចំនួនប្រជាជនសរុបបានកើនឡើងប្រហែល ៨ ភាគរយ បើប្រៀបធៀបនឹងតួលេខក្នុងឆ្នាំ ២០០៣ (៥៥ លាននាក់) ទោះបីជាតួលេខនេះមានលក្ខណៈខុសគ្នាទៅតាមប្រទេសនីមួយៗក៏ដោយ។ ចំនួនប្រជាជនក្នុងអាងទន្លេមេគង្គក្រោមបានកើនឡើង ២៥ ភាគរយនៅក្នុងប្រទេសកម្ពុជា ប្រហែល ៦ ភាគរយនៅក្នុងប្រទេសឡាវ នៅស្ថេរចំនួនដដែលនៅក្នុងប្រទេសថៃ និងកើនឡើងប្រហែល ១០ ភាគរយនៅក្នុងប្រទេសវៀតណាម។

ជាទូទៅ កម្រិតរស់នៅរបស់ប្រជាជនមានការកើនឡើង ប៉ុន្តែតំបន់ក្រីក្រធំៗជាច្រើននៅតែមាន ជាពិសេសនៅតំបន់ជនបទ។ សន្ទស្សន៍អភិវឌ្ឍន៍មនុស្សដែលផ្តល់ជាខ្នាតរង្វាស់នៃការរីកចម្រើនដោយប្រើនូវសន្ទស្សន៍ ដូចជា អាយុរស់នៅ ចំណេះដឹង និងកម្រិតនៃការរស់នៅ គឺមានការរីកចម្រើននៅក្នុងបណ្តាប្រទេសទាំងអស់ក្នុងអាងទន្លេមេគង្គក្រោម។ សន្ទស្សន៍អភិវឌ្ឍន៍មនុស្សរបស់ប្រទេសថៃគឺស្ថិតនៅខ្ពស់ជាងបន្តិចនៃមធ្យមរបស់សន្ទស្សន៍អភិវឌ្ឍន៍មនុស្សសម្រាប់ទ្វីបអាស៊ី ហើយសន្ទស្សន៍អភិវឌ្ឍន៍មនុស្សរបស់ប្រទេសវៀតណាម គឺប្រហាក់ប្រហែលនឹងមធ្យមរបស់សន្ទស្សន៍អភិវឌ្ឍន៍មនុស្សសម្រាប់ទ្វីបអាស៊ី ខណៈដែលសន្ទស្សន៍អភិវឌ្ឍន៍មនុស្សរបស់ប្រទេសឡាវ និងកម្ពុជា គឺទាបជាងមធ្យមរបស់សន្ទស្សន៍អភិវឌ្ឍន៍មនុស្សសម្រាប់ទ្វីបអាស៊ី។

ជីវភាព និងសន្តិសុខស្បៀងរបស់ប្រជាជនជនបទភាគច្រើនក្នុងអាងទន្លេនេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយទន្លេមេគង្គ និងបណ្តាញផ្លូវទឹករបស់វា។ ទន្លេនេះជាប្រភពនៃមច្ឆា និងផលិតផលជលផលដទៃទៀតសម្រាប់ប្រើប្រាស់ជាស្បៀង និងការរកប្រាក់ចំណូលទឹកសំរាប់ដាំដុះដំណាំ និងផ្លូវដឹកជញ្ជូនសម្រាប់ភ្ជាប់ទំនាក់ទំនងទៅកាន់ទីផ្សារ។ ទំនាក់ទំនងដ៏ជិតស្និទ្ធនេះ ក៏មានន័យថាប្រជាជននឹងងាយរងគ្រោះខ្លាំងផងដែរ ប្រសិនបើទន្លេ និងប្រព័ន្ធបរិស្ថានតំបន់ដីសើមមានការខូចខាត។

ប្រព័ន្ធបរិស្ថានចម្រុះដែលមាននៅក្នុងអាងទន្លេមេគង្គ ជាទីជម្រកដល់រុក្ខជាតិ និងសត្វផ្សេងៗជាច្រើនសន្ធឹកសន្ធាប់ដោយក្នុងនោះប្រភេទថ្មីៗជាច្រើនកំពុងតែត្រូវបានរកឃើញជាបន្តបន្ទាប់។ ប្រព័ន្ធបរិស្ថានតំបន់ដីសើម បានបម្រើផលប្រយោជន៍ជាច្រើន ក្នុង





នោះរួមមានការការពារពីទឹកជំនន់ និងការសំអាតទឹកសំអុយ។ ការប៉ុនប៉ងជាច្រើនត្រូវបានធ្វើឡើង ដើម្បីទាញយកតម្លៃសេដ្ឋកិច្ចពីផលប្រយោជន៍ទាំងនេះ ដូចនេះពួកវាមានសារៈសំខាន់ណាស់ដើម្បីយកទៅប្រើប្រាស់ក្នុងការធ្វើការសម្រេចចិត្ត។

ការត្រួតពិនិត្យទៅលើបណ្តាញផ្លូវទឹករបស់ទន្លេមេគង្គ បានបង្ហាញពីភាពធន់ទ្រាំរបស់ទន្លេទៅនឹងសម្ពាធថ្មីៗដែលបង្កឡើងដោយមនុស្ស។ គុណភាពទឹកនៅតំបន់ភាគច្រើន គឺមានលក្ខណៈល្អប្រសើរ លើកលែងតែនៅតំបន់ដីសណ្តទន្លេមេគង្គដែលកម្រិតខ្ពស់នៃសារធាតុចិញ្ចឹម ជាមូលហេតុនៃការព្រួយបារម្ភ។ ទឹកជំនន់ជារៀងរាល់ឆ្នាំរបស់ទន្លេមេគង្គនៅតែបន្តជួយផ្គត់ផ្គង់ដល់ការនេសាទត្រីដ៏សម្បូរបែប ថ្វីបើមានរបាយការណ៍នៃការថយចុះផលនេសាទក៏ដោយ។ ទោះបីជាយ៉ាងណាក៏ដោយស្ថានភាពព្រៃឈើ នៅក្នុងអាងទន្លេមេគង្គ មិនមានលក្ខណៈល្អប្រសើរឡើយ ដោយសារតែមានតម្រូវការឈើ និងដីព្រៃកាន់តែមានការកើនឡើង ដែលនាំទៅរកការកាប់បំផ្លាញព្រៃឈើ និងការសឹករិចរិល។

កសិកម្ម គឺជាសកម្មភាពសេដ្ឋកិច្ចសំខាន់បំផុតតែមួយគត់នៅក្នុងអាងទន្លេមេគង្គក្រោម ហើយការធ្វើបរកសិកម្ម គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពដែលប្រើប្រាស់ទឹកច្រើនជាងគេបំផុត។ ដំណាំស្រូវ គឺជាអាហារស្បៀងរបស់ប្រជាជន ហើយវាក៏ជាប្រភពចំណូលដ៏សំខាន់សម្រាប់អ្នកជនបទនៅក្នុងអាងទន្លេមេគង្គផងដែរ។ ចាប់តាំងពីទសវត្សឆ្នាំ ១៩៩០ ទិន្នផលមានការកើនឡើងជាលំដាប់នៅគ្រប់បណ្តាប្រទេសទាំងអស់ ដោយសារការកែលម្អបច្ចេកវិទ្យា និងការកើនឡើងនៃផ្ទៃដីស្រោចស្រព។

ការធ្វើនាវាចរណ៍នៅតាមដងទន្លេ មានការកើនឡើងជាលំដាប់ ដោយសារតែទន្លេមេគង្គបានក្លាយជាការភ្ជាប់ទំនាក់ទំនងដ៏សំខាន់ នៅក្នុងផ្លូវពាណិជ្ជកម្មអន្តរជាតិ ហើយក៏មានប្រជាប្រិយភាពកើនឡើងផងដែរ សម្រាប់វិស័យទេសចរណ៍។ នៅក្នុងតំបន់ខ្លះនៃអាងទន្លេនេះ ការធ្វើដំណើរតាមផ្លូវទឹក គឺជាមធ្យោបាយដឹកជញ្ជូនតែមួយគត់ ឬយ៉ាងហោចណាស់ក៏ជាមធ្យោបាយដឹកជញ្ជូនដ៏មានប្រសិទ្ធិភាពបំផុត ដែលគេអាចធ្វើបានស្ទើរពេញមួយឆ្នាំ។

ដោយសារតែកម្រិតជីវភាពរស់នៅ និងតម្រូវការថាមពលមានការកើនឡើង បានផ្តល់ជាឱកាសសម្រាប់ការអភិវឌ្ឍថាមពលវារីអគ្គិសនីនៅក្នុងប្រទេសឡាវ និងកម្ពុជា។

រដ្ឋាភិបាលនៃបណ្តាប្រទេសក្នុងអាងទន្លេនេះ បានទទួលស្គាល់ពីការអភិវឌ្ឍសក្តានុពលសេដ្ឋកិច្ចនៃប្រព័ន្ធទន្លេមេគង្គប្រកបដោយនិរន្តរភាព ក្នុងការកាត់បន្ថយភាពក្រីក្រ និងធ្វើឲ្យជីវភាពប្រជាជនកាន់តែប្រសើរឡើង។ ប៉ុន្តែឱកាសទាំងនេះត្រូវតែធ្វើឲ្យមានតុល្យភាពទៅនឹងផលប៉ះពាល់ទៅលើបរិស្ថាន ជលផល និងជីវភាពប្រជាជន។

របាយការណ៍ស្តីពី*ស្ថានភាពនៃអាងទន្លេ* ជាការប្រមែប្រមូលចំណេះដឹងមានស្រាប់ ដែលនឹងផ្តល់ជាប្រភពធនធានសម្រាប់រដ្ឋាភិបាល អ្នកគ្រប់គ្រងធនធាន និងអ្នកពាក់ព័ន្ធដទៃទៀតនៅក្នុងអាងទន្លេមេគង្គ។





# ប្រជាជន និងភាពក្រីក្រក្នុងអាងទន្លេមេគង្គក្រោម

ប្រជាជនជាច្រើនលាននាក់ ដែលកំពុងរស់នៅតាមតំបន់ភូមិសាស្ត្រផ្សេងៗនៃអាងទន្លេមេគង្គក្រោម ពឹងផ្អែកទៅលើទឹក និងផលនេសាទបានមកពីទន្លេសម្រាប់ធ្វើជាស្បៀង ប្រាក់ចំណូល ឱកាសចិញ្ចឹមជីវិត និងបែបបទនៃជីវិតរបស់ពួកគេ។ ពួកគេភាគច្រើនរស់នៅក្នុងលក្ខខណ្ឌក្រីក្រ ដោយមានអនាម័យ និងទឹកស្អាតប្រើប្រាស់តិចតួចប៉ុណ្ណោះ។ ជាមួយគ្នានោះដែរ ប្រជាជនមួយចំនួនប្រឈមមុខនឹងភាពមិនទៀងទាត់ ដូចជាទឹកជំនន់ និងមហន្តរាយផ្សេងៗ កង្វះកម្មសិទ្ធិដីធ្លី និងផលប៉ះពាល់ពីការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក។ ការពឹងផ្អែកយ៉ាងខ្លាំងទៅលើប្រភព ធនធានទឹកសម្រាប់ការចិញ្ចឹមជីវិត និងសន្តិសុខស្បៀង មានន័យថាប្រជាជនទាំងនោះងាយទទួលរងគ្រោះបំផុតនៅពេលដែលប្រភពធនធានទាំងនោះមានការថយចុះ ឬត្រូវបានបំផ្លិចបំផ្លាញ។

អង្គការកម្មវិធីអភិវឌ្ឍសហប្រជាជាតិ (UNDP) បានធ្វើចំណាត់ថ្នាក់បណ្តាប្រទេសទាំងអស់ក្នុងអាងទន្លេមេគង្គក្រោម ថាមានការអភិវឌ្ឍមនុស្សកម្រិតមធ្យម ដោយមានសន្ទស្សន៍អភិវឌ្ឍមនុស្សដែល ត្រូវបានកែលម្អយ៉ាងទៀងទាត់ នាប៉ុន្មានទសវត្សចុងក្រោយនេះ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រទេសដែលស្ថិតក្រោមមធ្យមភាគនៃសន្ទស្សន៍អភិវឌ្ឍមនុស្ស បានធ្វើឲ្យមានគម្លាតនៅក្នុងប្រទេសនីមួយៗ និងរវាងបណ្តាប្រទេសទាំងនោះ។

**សន្ទស្សន៍អភិវឌ្ឍមនុស្សក្នុងបណ្តាប្រទេសអាងទន្លេមេគង្គក្រោម (១៩៩០–២០០៧)**

| | សន្ទស្សន៍អភិវឌ្ឍមនុស្ស | | | |
|---|---|---|---|---|
| | ១៩៩០ | ១៩៩៥ | ២០០០ | ២០០៧ |
| កម្ពុជា | មិនដឹង | ០.៥៤០ | ០.៥៤៧ | ០.៥៩៣ |
| ឡាវ | ០.៤៧៨ | ០.៥២៤ | ០.៥៦៣ | ០.៦១៩ |
| ថៃ | ០.៧១២ | ០.៧៤៥ | ០.៧៦១ | ០.៧៨៣ |
| វៀតណាម | ០.៥៩០ | ០.៦៧២ | ០.៧១១ | ០.៧២៥ |
| មធ្យមសំរាប់ទ្វីបអាស៊ី | | | | ០.៧២៤ |

ថ្វីបើមានកំណើនសេដ្ឋកិច្ចយ៉ាងលឿនក៏ដោយ នាពីរទសវត្សចុងក្រោយនេះ កម្ពុជានៅតែជាប្រទេសមួយក្នុងចំណោមប្រទេសក្រីក្របំផុតនៅក្នុងពិភពលោក។ ប្រជាជន ៣៥ ភាគរយ រស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ ប៉ុន្តែភាគច្រើនពួកគេរស់នៅក្នុងតំបន់ជនបទ ដែលអ្នកជនបទមានប្រមាណជា ៨០ ភាគរយ នៃប្រជាជនសរុប។ កំណើនសេដ្ឋកិច្ចកំពុងកើនឡើង ដោយក្នុងនោះកសិកម្មដែលជាវិស័យសំខាន់ដែលបានផ្តល់ការងារចំនួន ៧០ ភាគរយ នៃកម្លាំងពលកម្ម។ ប្រហែលជា ២៤ ភាគរយ នៃប្រជាជន ទំនងជាមិនអាចមានជីវិតរស់រានរហូតដល់អាយុ ៤០ ឆ្នាំ បានទេ ខណៈពេលដែលប្រជាជន ៣៥ ភាគរយ ខ្វះខាតប្រភពទឹកស្អាតប្រើប្រាស់ ហើយកុមារក្រោមអាយុ ៥ ឆ្នាំ ចំនួន ៣៦ ភាគរយ មិនគ្រប់ទម្ងន់។





ក៏ដូចគ្នានេះដែរ នៅក្នុងប្រទេសឡាវ ភាពក្រីក្រកំពុងរីករាលដាល ដោយប្រជាជនចំនួន ៣៣ ភាគរយ ស្ថិតក្រោមបន្ទាត់នៃភាពក្រីក្រ។ ពាក់កណ្តាលនៃចំនួនគ្រួសារទាំងអស់មិនមានទឹកប្រើប្រាស់ប្រកបដោយសុវត្ថិភាពទេ ហើយពាក់កណ្តាលនៃភូមិទាំងអស់ គឺមិនអាចធ្វើដំណើរទៅដល់តាមផ្លូវថ្នល់ក្នុងអំឡុងរដូវវស្សាទេ។ ភាពក្រីក្រមានច្រើនជាងគេនៅតំបន់ខ្ពង់រាបខាងត្បូងជាប់ព្រំដែនប្រទេសវៀតណាម។ អត្រាទាបនៃភាពក្រីក្រ ស្ថិតនៅតាមបណ្តាភូមិនៃតំបន់ភ្នំនៅប៉ែកខាងជើងប្រទេស ហើយភាពក្រីក្រមានកម្រិតទាបបំផុតនៅតាមទីប្រជុំជនខាងក្នុង និងជុំវិញទីក្រុងធំៗ។ រយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ អាយុកាលរស់នៅមធ្យមបានកើនឡើងជាលំដាប់ជាពិសេសក្នុងប្រទេសឡាវ ដែលបានកើនឡើងពី ៥៤ ឆ្នាំ ក្នុងឆ្នាំ ២០០០ ដល់ ៦៤ ឆ្នាំ ក្នុងឆ្នាំ ២០០៧ ទោះបីជាអាយុកាលរស់នៅមធ្យម ក្នុងប្រទេសឡាវ និងកម្ពុជាបន្តស្ថិតនៅទាបជាងអាយុកាលរស់នៅមធ្យម ៦៩ ឆ្នាំ របស់បណ្តាប្រទេសកំពុងអភិវឌ្ឍ នៅអាស៊ីខាងកើត និងប៉ាស៊ីហ្វិកក៏ដោយ។

ទោះបីជាមានការកែលម្អជាច្រើន នារយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះក៏ដោយ លក្ខខណ្ឌសុខភាពរបស់កុមារនៅប្រទេសកម្ពុជា និងឡាវនៅតែមានលក្ខណៈមិនល្អ ។ ពីឆ្នាំ២០០០ ដល់ ២០០៦ អត្រាមរណៈភាពទារកក្នុងប្រទេសកម្ពុជាបានធ្លាក់ចុះពី ៨៨ ក្នុង ១០០០ នៃការផ្តល់កំណើត រហូតដល់ ៦៥ ហើយនៅក្នុងប្រទេសឡាវ វាបានធ្លាក់ចុះពី ៩២ ដល់ ៥៩ ដែលប្រទេសទាំងពីរនេះ នៅតែស្ថិតខ្ពស់ជាងមធ្យមនៃតំបន់អាស៊ីអាគ្នេយ៍ដែលមានត្រឹមតែ២៧ប៉ុណ្ណោះ។

នៅក្នុងប្រទេសថៃ និងវៀតណាម កម្រិតនៃការអភិវឌ្ឍមានលក្ខណៈល្អប្រសើរណាស់។ ប្រទេសថៃសម្រេចបាននូវគោលដៅអភិវឌ្ឍសហស្សវត្សទាំងប្រាំបួនចំណុចមុនឆ្នាំកំណត់២០១៥។ សមាមាត្រនៃប្រជាជនដែលរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ ត្រូវបានកាត់បន្ថយពី ២៧ ភាគរយ ក្នុងឆ្នាំ ១៩៩០ ដល់ ១២ ភាគរយ ក្នុងឆ្នាំ ២០០៤។

ប្រទេសវៀតណាមបានធ្វើឲ្យមានការរីកចម្រើនយ៉ាងខ្លាំង ក្នុងការជំនះនឹងភាពក្រីក្រ ដោយធ្វើឲ្យចំនួនប្រជាជនស្ថិតក្រោមបន្ទាត់នៃភាពក្រីក្រ មានការធ្លាក់ចុះយ៉ាងច្រើនពី ៧៥ ភាគរយ ក្នុងឆ្នាំ ១៩៩០ រហូតដល់ ១៦ ភាគរយ ក្នុងឆ្នាំ ២០០៦ ទោះបីជាភាពខុសគ្នាខ្លាំងបានកើតមានឡើង រវាងប្រជាជនតំបន់ជនបទ និងទីក្រុងក៏ដោយ ក្នុងនោះអត្រានៃភាពក្រីក្រនៅជនបទមាន ៤៥ ភាគរយ និងនៅទីក្រុងមាន ១៨ ភាគរយ។ ជនជាតិភាគតិចមិនទាន់បានទទួលផលប្រយោជន៍ពីការអភិវឌ្ឍ រយៈពេលប៉ុន្មានទសវត្សនេះនៅឡើយទេ ជាពិសេសនៅតំបន់ជនបទដែលកម្រិតជីវភាពរស់នៅ ត្រូវបានធ្វើឲ្យប្រសើរឡើងក្នុងកម្រិតតិចតួចប៉ុណ្ណោះ។

ដីសណ្តទន្លេមេគង្គក្នុងប្រទេសវៀតណាម ដែលជាតំបន់កសិកម្មមានប្រជាជនរស់នៅច្រើនជាងគេបំផុតនោះ មានប្រជាជនច្រើនជាង ១៧ លាននាក់ ( ២១ ភាគរយនៃប្រជាជនវៀតណាមសរុប)។ តំបន់ដីសណ្តនេះបានក្លាយជាតំបន់កសិកម្មសំខាន់ជាងគេបំផុតក្នុងប្រទេសវៀតណាម ដោយផលិតបានលើសពី ៥០ ភាគរយ នៃដំណាំស្រូវ និង ៦០ ភាគរយ នៃផលិតកម្មត្រី។







# ការចិញ្ចឹមជីវិតពឹងផ្អែកទៅលើ អាងទន្លេដ៏មានសារៈសំខាន់

ប្រព័ន្ធបរិស្ថានចម្រុះរបស់អាងទន្លេមេគង្គ គឺជាមូលដ្ឋានគ្រឹះនៃការចិញ្ចឹមជីវិតដ៏សម្បូរបែប និងផ្តល់ជាសន្តិសុខស្បៀងសម្រាប់ប្រជាជនភាគច្រើននៃប្រជាជនតំបន់ជនបទរស់នៅក្នុងអាងទន្លេនេះ។ វាលស្រែលិចទឹក ត្រូវបានប្រើប្រាស់ដើម្បីដាំដុះស្រូវ និងការនេសាទត្រីដ៏ច្រើនសន្ធឹកសន្ធាប់ដែលជាប្រភពនៃប្រូតេអ៊ីន និងប្រាក់ចំណូលសម្រាប់អ្នកជនបទរស់នៅក្នុងអាងទន្លេនេះ។ ផ្ទៃដីព្រៃមួយភាគធំជាតំបន់ជីវចម្រុះ ហើយបានផ្តល់ជាអុស និងផលិតផលដទៃទៀតសម្រាប់ប្រជាជនរស់នៅក្នុងតំបន់នោះ។

## កសិកម្មត្រូវបានបង្កើតឡើងនៅលើដីទន្លេដ៏មានជីជាតិ

កសិកម្ម គឺជាសកម្មភាពសេដ្ឋកិច្ចសំខាន់បំផុតតែមួយគត់នៅអាងទន្លេមេគង្គក្រោម។ ផ្ទៃដីដាំដុះច្រើនជាង ១០ លានហិចតា ត្រូវបានប្រើប្រាស់ដើម្បីដាំដុះដំណាំស្រូវដែលជាដំណាំស្បៀងសម្រាប់ប្រជាជនភាគច្រើនរស់នៅក្នុងតំបន់នេះ។ នៅលើផ្ទៃដីផលិតកម្មភាគច្រើននៃដីសណ្តទន្លេមេគង្គ កសិករអាចដាំដុះដំណាំស្រូវបាន ៣ ដង ក្នុងមួយឆ្នាំ។ ទិន្នផលស្រូវមានពី ១ តោន រហូតដល់ច្រើនជាង ៥ តោន ក្នុងមួយហិចតា។ នៅឆ្នាំ ២០០៥ ស្រូវប្រហែលជា ៣៣.៨ លានតោន ត្រូវបានផលិតនៅក្នុងអាងទន្លេមេគង្គក្រោម ដែលលើសពីពាក់កណ្តាលនៃចំនួននេះ ត្រូវបានផលិតដោយប្រទេសវៀតណាម។ ចំពោះអ្នកជនបទ ច្រើនជាងពាក់កណ្តាលនៃអ្នកជនបទរស់នៅក្នុងអាងទន្លេមេគង្គ ការលក់ស្រូវ គឺជាប្រភពនៃប្រាក់ចំណូលដ៏សំខាន់។

ក្នុងបណ្តាប្រទេសអាងទន្លេមេគង្គក្រោមទាំងអស់ ទិន្នផលស្រូវមានការកើនឡើងជាលំដាប់ ប្រហែល ៣ ភាគរយ ចាប់តាំងពីទសវត្សឆ្នាំ ១៩៩០មក។ ក្នុងប្រទេសកម្ពុជា ទិន្នផល និងផលិតកម្មដំណាំស្រូវប្រាំង និងស្រូវវស្សាមានការកើនឡើងជាលំដាប់។ ក្នុងប្រទេសឡាវ ប្រព័ន្ធផលិតកម្មដំណាំស្រូវសំខាន់ជាងគេបំផុត គឺស្រូវទំនាបជួរវស្សា ដែលកាន់តែរីកធំឡើងៗ។ ផ្ទុយទៅវិញ ផ្ទៃដីដំណាំស្រូវតំបន់ខ្ពង់រាបដែលជាទូទៅមានជាប់ពាក់ព័ន្ធនឹងកសិកម្មពនេចរ មានការថយចុះ។ នៅក្នុងតំបន់ដីសណ្តប្រទេសវៀតណាម ទោះបីផ្ទៃដីកសិកម្មមានការថយចុះនាពីទសវត្សចុងក្រោយនេះក៏ដោយ ក៏ការកើនឡើងនូវផលិតភាពធ្វើឲ្យផលិតកម្មកើនឡើង។ ទោះបីជាយ៉ាងណាក៏ដោយ ផលិតភាពដែលកើនឡើងនេះ គឺមានការជាប់ទាក់ទងនឹងការប្រើប្រាស់ថ្នាំពុលកសិកម្មច្រើនហួសប្រមាណ ហើយជាលទ្ធផល ផ្ទៃដីស្រែប្រាំងជាច្រើនក្នុងដីសណ្តប្រទេសវៀតណាម មិនមានលក្ខណៈសមស្របសម្រាប់ការចិញ្ចឹមត្រីឡើយ។ នៅភាគឥសាននៃប្រទេសថៃ ផ្ទៃដីច្រើនជាង ៨០ ភាគរយ នៃផ្ទៃដីដាំដុះទាំងអស់ ត្រូវបានប្រើប្រាស់ដើម្បីដាំដុះដំណាំស្រូវ ឬដាំលាយគ្នារវាងដំណាំស្រូវ និងដំណាំតំបន់ខ្ពស់។ ចន្លោះឆ្នាំ ២០០០ និងឆ្នាំ ២០០៥ ផ្ទៃដីប្រមូលផលស្រូវក្នុងប្រទេសថៃមានការធ្លាក់ចុះបន្តិច។




ដំណាំស្រូវនៅតែជាមូលដ្ឋាននៃវិស័យកសិកម្មក្នុងអាងទន្លេមេគង្គក្រោម នាប៉ុន្មានទសវត្សខាងមុខនេះ ។ នារយៈពេល ២០ ឆ្នាំ ខាងមុខ ផលិតកម្មត្រូវបានព្យាករណ៍ថានឹងមានលក្ខណៈល្អប្រសើរអាចជំនះបានទៅនឹងកំណើននៃចំនួនប្រជាជន។ ផលិតកម្មដែលកើនឡើងនេះ បានមកពីការកើនឡើងនៃផ្ទៃដីស្រោចស្រព និងការកើនឡើងនៃទិន្នផលគ្រាប់។

វិស័យស្រោចស្រព ត្រូវបានប្រើប្រាស់ទឹកច្រើនជាងគេបំផុតនៅអាងទន្លេមេគង្គក្រោម ដោយប្រើប្រាស់ទឹកសាបប្រមាណជា ៤១.៨ កោដិម៉ែត្រគូប ក្នុងមួយឆ្នាំ។ លើសពីពាក់កណ្តាលនៃការប្រើប្រាស់ទឹកនេះ ត្រូវបានប្រើប្រាស់ក្នុងប្រទេសវៀតណាមដែលតាមពីក្រោយដោយប្រទេសថៃ ឡាវ និងកម្ពុជា។ ចាប់តាំងពីឆ្នាំ ១៩៩០ ផ្ទៃដីស្រោចស្រពត្រូវបានពង្រីកបន្តិចម្តងៗ ក្នុងបណ្តាប្រទេសទាំងបួននៃអាងទន្លេមេគង្គក្រោម។ ការវាយតម្លៃថ្មីៗនេះទៅលើការស្រោចស្រពក្នុងអាងទន្លេមេគង្គក្រោម បានចុះបញ្ជីគម្រោងស្រោចស្រពចំនួន ១៥,០០០ គម្រោង ដែលមានចាប់ពីគម្រោងតូចរហូតដល់គម្រោងខ្នាតធំ និងចាប់ពីការស្រោចស្រពដោយបង្ហូរ រហូតដល់ការស្រោចស្រពដោយប្រើម៉ាស៊ីនបូមទឹក។ ក្រៅពីការប្រើប្រាស់ដើម្បីដាំដុះដំណាំស្រូវ វាលស្រែបានផ្តល់ផលប្រយោជន៍ផ្សេងៗទៀតជាច្រើន ដូចជា ផ្តល់ទីជម្រកសម្រាប់ត្រី និងប្រភេទសត្វដទៃទៀត ដូចជា ពពួកសិប្បីសត្វ និងកង្កែបដែលជាប្រភពអាហារមួយដ៏សំខាន់។ ពួកវាក៏ដើរតួនាទីយ៉ាងសំខាន់ក្នុងការកាត់បន្ថយទឹកជំនន់។

និន្នាការយ៉ាងសំខាន់ក្នុងវិស័យកសិកម្មរបស់អាងទន្លេនេះគឺការរីករាលដាលយ៉ាងលឿននៃចំការធំៗសម្រាប់ការផលិតជាលក្ខណៈពាណិជ្ជកម្មនៃដំណាំកៅស៊ូ និងដំណាំផ្តល់ប្រេង ដែលមួយផ្នែកគឺដោយសារការឡើងថ្លៃប្រេងឥន្ធនៈ និងការកើនឡើងនៃតម្រូវការនាំចេញជីវឥន្ធនៈទៅកាន់ទីផ្សារជិតខាង។ ការពង្រីកវិស័យកសិកម្មបានបង្កើតជាបញ្ហាប្រឈមធ្ងន់ធ្ងរដល់ការបាត់បង់ ជីវចម្រុះ និងគម្របព្រៃឈើ ដោយសារតែវិស័យកសិកម្មជាមូលហេតុ ចម្បងនៃការកាប់បំផ្លាញព្រៃឈើក្នុងអាងទន្លេមេគង្គក្រោម។ ប៉ុន្មាន ឆ្នាំចុងក្រោយនេះ ការកាប់រានដីព្រៃសម្រាប់វិស័យកសិកម្មបានបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់គម្របព្រៃឈើ ជាជាងការកាប់ឈើទៀតផង។







# ព្រៃឈើជាគន្លឹះនៃការគ្រប់គ្រង ទីជម្រាលប្រកបដោយនិរន្តរភាព

ការអភិវឌ្ឍសេដ្ឋកិច្ច ទាំងក្នុងកម្រិតសកល និងកម្រិតជាតិ កំពុងបង្កើតជាសម្ពាធដ៏ធ្ងន់ធ្ងរដល់ព្រៃឈើនៃបណ្តាប្រទេសទន្លេមេគង្គក្រោម។ កំណើនប្រជាជន ការអភិវឌ្ឍដែលកាន់តែរីកធំឡើងៗ និងផលប៉ះពាល់នៃគម្រោង សុទ្ធតែជះឥទ្ធិពលដល់ទេសភាពតំបន់ព្រៃឈើទាំងនោះ។

ផ្ទៃដីព្រៃឈើក្នុងបណ្តាប្រទេសអាងទន្លេមេគង្គក្រោម មានសរុប ៥៤ លានហិចតា ស្មើនឹង ៤៣ ភាគរយ នៃផ្ទៃដីសរុប។ ទោះបីផ្ទៃដីព្រៃឈើដែលទុកសម្រាប់ការអភិរក្ស បានកើនឡើងប្រហែលមួយភាគបីក្នុងចន្លោះឆ្នាំ ១៩៩០ និងឆ្នាំ ២០០៥ ដោយសារតែគោលនយោបាយការពារបរិស្ថាន និងវិធានការដើម្បីជំរុញការដាំព្រៃឈើឡើងវិញត្រូវទទួលបានការគាំទ្រក៏ដោយ ក៏ផ្ទៃដីព្រៃឈើសំខាន់ (ព្រៃមិនទាន់រងការបំផ្លិចបំផ្លាញ)នៅក្នុងតំបន់នេះ បានបន្តធ្លាក់ចុះ។ គុណភាពនៃធនធានព្រៃឈើ ក៏មានការធ្លាក់ចុះផងដែរ ដោយសារតែព្រៃឈើសំខាន់ជាច្រើន (ព្រៃមិនទាន់រងការបំផ្លិចបំផ្លាញ) បានក្លាយជាព្រៃបន្ទាប់បន្សំ (ព្រៃដាំឡើងវិញ) ហើយចំការឯកវប្បកម្មធំៗក៏កាន់តែរីកធំឡើងៗ។

គម្របព្រៃឈើក្នុងបណ្តាប្រទេសអាងទន្លេមេគង្គក្រោម




ចន្លោះពីឆ្នាំ ១៩៩០ ដល់ឆ្នាំ ២០០៥ ប្រទេសវៀតណាមបាត់បង់ ១០ ភាគរយ ក្នុងមួយឆ្នាំៗ នៃគម្របព្រៃឈើសំខាន់ដែលនៅសល់ ខណៈដែលប្រទេសកម្ពុជាបាត់បង់ ៦ ភាគរយ ជារៀងរាល់ឆ្នាំ។ ការប្រែប្រួលធនធានព្រៃឈើក្នុងប្រទេសថៃ និងវៀតណាម បានចាប់ផ្តើមដើរតាមគន្លងរបស់ប្រទេសឡាវ និងកម្ពុជា។ ក្នុងប្រទេសវៀតណាមដែលជាកន្លែងដែលតម្រូវការផលិតផលព្រៃឈើ នៅតែមានកម្រិតខ្ពស់ កម្មវិធីដាំដើមឈើជាចម្ការធំៗមានន័យថា ផ្ទៃដីព្រៃឈើសរុបកំពុងតែរីកធំឡើងៗ ស្របពេលដែលប្រទេសថៃមានផលិតកម្មស្ទើរទ្វេដងនៃផលិតផលក្រដាសក្នុងមួយទសវត្សចុងក្រោយនេះ។

ក្នុងប្រទេសថៃ វិធានការការពារព្រៃឈើដែលត្រូវបានអនុវត្តរយៈពេល ២ ទសវត្ស ចុងក្រោយនេះ កំពុងតែផ្តល់លទ្ធផល។ ទោះបីជាផ្ទៃដីព្រៃឈើសរុបនៅតែធ្លាក់ចុះក៏ដោយ ក៏កម្រិតនៃការបាត់បង់នេះមានការថយចុះផងដែរ។ ចម្ការម៉ៃសាក់ និងចម្ការដើមឈើសម្រាប់ធ្វើក្រដាស បានបង្កើតជាផ្នែកមួយយ៉ាងសំខាន់ និងកាន់តែរីកធំឡើងៗនៃធនធានព្រៃឈើជាតិ ក្នុងនោះរួមមានតំបន់ចម្ការការពាររក្សាទុក ចំនួន ១.១ លានហិចតា។

ប្រទេសឡាវ និងកម្ពុជា នៅតែស្ថិតក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍព្រៃឈើ។ នៅក្នុងប្រទេសកម្ពុជា ទំហំផ្ទៃដីចម្ការមានការកើនឡើងតិចតួចណាស់ ស្របពេលដែលការរានដីព្រៃធម្មជាតិនៅតែមានកម្រិតខ្ពស់។ ក្នុងប្រទេសឡាវ ចម្ការជាច្រើនកំពុងត្រូវបានបង្កើតក្នុងអត្រាកើនឡើង ទោះបីជាផ្ទៃដីទាំងនោះនៅមានទំហំតូចក៏ដោយ។







ប្រសិនបើការកាប់បំផ្លាញព្រៃឈើនៅតែបន្ត ដូចកម្រិតក្នុងចន្លោះឆ្នាំ ២០០០ – ២០០៥ កម្ពុជានឹងបាត់បង់ព្រៃឈើបន្ថែមទៀតប្រមាណ ២.៧ លានហិចតា នៅឆ្នាំ ២០២០ ស្របពេលដែលប្រទេសឡាវនឹងបាត់បង់ ១.១ លានហិចតា និងប្រទេសថៃបាត់បង់ ៨០០,០០០ ហិចតា ខណៈពេលដែលវៀតណាម នឹងបង្កើនគម្របព្រៃឈើរបស់ខ្លួនដោយភាគច្រើនតាមរយៈការអភិវឌ្ឍជាចម្ការធំៗ ប្រមាណជា ៤.៤ លានហិចតា។

ក្នុងប្រទេសឡាវ កម្ពុជា និងវៀតណាម តំបន់ការពារដែលនៅក្បែរនឹងតំបន់អភិវឌ្ឍ គឺស្ថិតក្រោមការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរនៃការបាត់បង់ធនធាន និងជីវចម្រុះ។ ឈើហ៊ុប សត្វព្រៃ និងអនុផលព្រៃឈើ ត្រូវបានប្រមូលផលយ៉ាងច្រើនហួសប្រមាណដែលបណ្តាលឲ្យមានការបំផ្លិចបំផ្លាញដល់ទីជម្រក និងបរិស្ថាន ហើយក៏ធ្វើឲ្យអន្តរាយដល់ជីវភាពប្រជាជនក្នុងតំបន់នោះផងដែរ។

ក្រៅពីការកាប់ដើមឈើដ៏ខ្លាំងក្លា ភ្លើងឆេះព្រៃបានក្លាយជាមូលហេតុចម្បងនៃការបាត់បង់ព្រៃឈើដែលបង្កជាការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់លំនឹងប្រព័ន្ធអេកូឡូស៊ី។ កសិករប្រើប្រាស់ភ្លើងដើម្បីរុករានដី និងជួយជំរុញដល់ការដាំដុះសារជាថ្មី ហើយការឆេះដែលមានកម្លាំងខ្សោយ ត្រូវបានប្រើប្រាស់ដើម្បីកាត់បន្ថយការដុះរបស់ព្រៃ។ ប៉ុន្តែជារៀងរាល់ឆ្នាំ ភ្លើងឆេះព្រៃដែលមិនអាចគ្រប់គ្រងបាន បានឈានទៅដល់ការបំផ្លាញព្រៃឈើជាទ្រង់ទ្រាយធំ។ ជាមួយនឹងការកើនឡើងនៃចំនួនផ្លូវថ្នល់ និងសកម្មភាពមនុស្សកើនឡើងក្នុងតំបន់ដែលកាលពីមុនជាតំបន់ដាច់ស្រយាលនោះ បើគ្មានវិធានការទប់ស្កាត់ទេ ទំនងជាចំនួននៃភ្លើងឆេះព្រៃ មានការកើនឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ ដែលបណ្តាលឲ្យមានការខូចខាតដល់ព្រៃឈើ។

អនុផលព្រៃឈើដូចជា ផ្តៅនិងឫស្សី រុក្ខជាតិឱសថ និងប្រេងរុក្ខជាតិ ជាប្រភពប្រាក់ចំណូលដ៏សំខាន់សម្រាប់ប្រជាជនរាប់ពាន់នាក់ដែលរស់នៅអាស្រ័យលើព្រៃឈើក្នុងអាងទន្លេមេគង្គក្រោម ហើយវាក៏បានផ្តល់ជាសំណាញ់សន្តិសុខក្នុងពេលទុរភិក្សផងដែរ។ ផលិតផលមួយចំនួនក្នុងចំណោមផលិតផលទាំងនេះ ប្រព័ន្ធផលិតកម្មប្រកបដោយនិរន្តរភាព ត្រូវបានអភិវឌ្ឍឡើង ប៉ុន្តែចំពោះផលិតផលដទៃទៀត ដូចជា ផ្តៅ ការប្រមូលផលច្រើនហួសប្រមាណ គឺជាបញ្ហាមួយកំពុងរីករាលដាល ដែលគំរាមកំហែងដល់ឧស្សាហកម្មដ៏មានសារៈសំខាន់នេះ។





# ការនេសាទត្រីដែលធំជាងគេបំផុតក្នុងពិភពលោកបាន ចិញ្ចឹមបីបាច់ដល់អាងទន្លេនេះ

ដោយមានផលិតកម្មសរុបចំនួនប្រហែល ៣.៨ លានតោន ក្នុងឆ្នាំ ២០០៨ ក្នុងនោះមាន ២.១ លានតោន បានមកពីការនេសាទត្រី និង ១.៧ លានតោន បានមកពីវារីវប្បកម្មការនេសាទត្រីក្នុងដែនដីនៃអាងទន្លេមេគង្គ គឺស្ថិតក្នុងចំណោមផលិតកម្មត្រីធំជាងគេបំផុតក្នុងពិភពលោក។ តម្លៃសេដ្ឋកិច្ចសរុបនៃការនេសាទត្រីទន្លេមេគង្គមានប្រមាណជា ៥.៦-៩.៤កោដិដុល្លារ ក្នុងមួយឆ្នាំៗ។ តម្លៃសេដ្ឋកិច្ចនេះ គួរតែត្រូវបានរួមបញ្ចូលផងដែរនូវតម្លៃ នៃការនេសាទត្រីដែលគ្រប់គ្រាន់សម្រាប់តែទទួលទាន ដែលជាប្រភពអាហារមួយសម្រាប់មនុស្សរាប់លាននាក់រស់នៅក្នុងតំបន់អាងទន្លេនេះ។

ការនេសាទត្រីទន្លេមេគង្គ ក៏បានជួយដល់សហគ្រាសរាប់សែនផងដែរ ដែលមានចាប់តាំងពីហាង និងតូបលក់អាហារដែលបានជួយផ្គត់ផ្គង់ដល់គ្រួសារអ្នកនេសាទរហូតដល់អ្នកសាងសង់ទូក និងអ្នកផ្គត់ផ្គង់ឧបករណ៍ពាក់ព័ន្ធនឹងការនេសាទ។

ស្ថិតក្រោមមូលដ្ឋានតម្លៃនៃការនេសាទត្រីទន្លេមេគង្គគិតជាដុល្លារ គឺជាសារៈសំខាន់នៃការនេសាទត្រីសម្រាប់សេដ្ឋកិច្ចគ្រួសារ។ ក្នុងប្រទេសឡាវ ប្រជាជនច្រើនជាងពាក់កណ្ដាលជាអ្នកនេសាទត្រី ហើយការនេសាទត្រីបានផ្ដល់ប្រាក់ចំណូល ២០ ភាគរយ នៃប្រាក់ចំណូលក្នុងគ្រួសារ។ នៅភាគខាងត្បូងនៃប្រទេស ការនេសាទត្រីរឹតតែមានសារៈសំខាន់ណាស់ ហើយប្រជាជន ៨០ ភាគរយ ជាអ្នកនេសាទត្រី។ ប្រាក់ចំណូលបានមកពីការនេសាទត្រី បានផ្ដល់ជាថវិកាសម្រាប់ទិញគ្រាប់ពូជស្រូវនៅចុងរដូវប្រាំង ដែលអូសបន្លាយរយៈពេលយូរ ប៉ុន្តែតម្លៃរបស់វាក៏ត្រូវបានបង្ហាញផងដែរ ដោយសារតួនាទីដ៏សំខាន់របស់វានៅក្នុងសន្តិសុខស្បៀង និងចំណីអាហារ។

ការនេសាទត្រីក្នុងទន្លេមេគង្គ ដើរតួនាទីយ៉ាងសំខាន់ក្នុងការចិញ្ចឹមបីបាច់ប្រជាជនរស់នៅក្នុងអាងទន្លេនេះ។ ត្រី គឺជាប្រភពនៃប្រតេអ៊ីនសាច់ដ៏សំខាន់ និងជាប្រភពនៃមីក្រូសារធាតុចិញ្ចឹមជីវិតដ៏ចាំបាច់។ ការបរិភោគត្រី និងធនធានជលផលដទៃទៀតក្នុងអាងទន្លេនេះ មានចាប់ពី ២៩-៣៩ គីឡូក្រាម សម្រាប់មនុស្សម្នាក់ក្នុងមួយឆ្នាំ ដែលជាអត្រាមួយខ្ពស់ក្នុងចំណោមអត្រាខ្ពស់ៗជាងគេបំផុតក្នុងពិភពលោក។

ការនេសាទត្រីក្នុងអាងទន្លេមេគង្គក្រោម ភាគច្រើនជាការនេសាទខ្នាតតូចជាលក្ខណៈគ្រួសារ ដែលនេសាទបានត្រីភាគច្រើននៃបរិមាណត្រីដែលនេសាទបានសរុប។ នៅទូទាំងតំបន់អាងទន្លេមេគង្គក្រោមនេះ អ្នកនេសាទត្រីសុទ្ធតែអះអាងពីការធ្លាក់ចុះនៃបរិមាណត្រី ការថយចុះនៃទំហំមធ្យមរបស់ត្រី និងការថយចំនួននៃប្រភេទត្រីស៊ីសាច់ធំៗដែលពួកគេនេសាទបាន។ ទោះបីជាការពិនិត្យតាមដានការនេសាទត្រីដោយប្រើឧបករណ៍ដាយ ក្នុងទន្លេសាប រយៈពេលលើសពី ១២ ឆ្នាំ នេះ មិនបានបង្ហាញពីការធ្លាក់ចុះនៃបរិមាណត្រីដែលនេសាទបានក៏ដោយ ក៏វាបានបង្ហាញពីសញ្ញានៃការនេសាទត្រីច្រើនហួសប្រមាណផងដែរ ពោលគឺមានការធ្លាក់ចុះនៃបរិមាណត្រីធំៗ ដែលស៊ីរុក្ខជាតិ និងនេសាទបានច្រើនលើសលប់នូវប្រភេទត្រីតូចៗ។

**ការប៉ាន់ស្មានការបរិភោគផលិតផលជលផល ងអាងទន្លេមេគង្គក្រោម (២០០៨)**

| ប្រទេស | ក្នុងដែនដី | | | ផលិតផល សមុទ្រ* | ផលិតផល សរុប |
|---|---|---|---|---|---|
| | ត្រី | វារីសត្វដទៃទៀត | ត្រី និងវារីសត្វ | | |
| កម្ពុជា | ៥៥៥ | ១២១ | ៦៧៦ | ១៣ | ៦៨៩ |
| ឡាវ | ១៨៥ | ៤៥ | ២៣០ | ៣ | ២៣២ |
| ថៃ | ៧៤០ | ១៩៦ | ៩៣៧ | ១៣៤ | ១០៧០ |
| វៀតណាម | ៧៤៦ | ១៧៣ | ៩២០ | ១៤០ | ១០៥៩ |
| សរុប | ២២១៧ | ៥៣៥ | ២៧៥២ | ២៩៤ | ៣០៤៥ |



ការសិក្សារយៈពេលបីឆ្នាំទៅលើបរិមាណត្រីដែលត្រូវនេសាទបាន ដោយអ្នកនេសាទលក្ខណៈពាណិជ្ជកម្ម បានបង្ហាញពីនិន្នាការប្រែប្រួលទៅតាមពេលវេលា ប៉ុន្តែបរិមាណត្រីដែលនេសាទបានទាំងនេះមានទំនាក់ទំនងជាមួយបំលាស់ទីរបស់ហ្វូងត្រី ដែលបំលាស់ទីទាំងនេះមានការជាប់ទាក់ទងនឹងកម្ពស់ និងលំហូររបស់ទឹកទន្លេ។

បរិស្ថានលិចទឹកតំបន់ត្រូពិច មានលក្ខណៈឆាប់ត្រឡប់ទៅរកភាពដើមវិញណាស់ បន្ទាប់ពីរងសម្ពាធនៃការនេសាទដោយសារតែចំនួនកូនញាស់របស់ត្រីដ៏លើសលប់ត្រូវបានបង្កើតឡើង ជារៀងរាល់ឆ្នាំនៅលើផ្ទៃដីដ៏ធំល្វឹងល្វើយនៃតំបន់លិចទឹកនារដូវទឹកជំនន់។ ឧទាហរណ៍ ការប្រែប្រួលបរិស្ថានទាំងនេះតាមរយៈការសាងសង់ទំនប់ទឹក ផ្លូវ និងហេដ្ឋារចនាសម្ព័ន្ធដទៃទៀត ការទប់ទឹកសម្រាប់ការប្រើប្រាស់ផ្សេងៗ ការរុករានព្រៃលិចទឹក ការកាប់បំផ្លាញព្រៃនៃតំបន់អាងធម្មជាតិ និងផលប៉ះពាល់នៃការបំពុលទឹកសុទ្ធតែជាមូលហេតុនៃការថយចុះផលនេសាទដែលធ្វើឲ្យបរិមាណត្រីដែលនេសាទមានការធ្លាក់ចុះ។

តួនាទីរបស់ទឹកជំនន់ជាអ្នកជួយដល់ការបង្កបង្កើតកូនត្រី សារៈសំខាន់នៃបំលាស់ទីទៅកាន់តំបន់លិចទឹក និងតម្រូវការរបស់ត្រីដើម្បីផ្លាស់ទីទៅកាន់ទីជម្រកទាំងឡាយ ដែលស្ថិតដាច់ឆ្ងាយពីគ្នាបានបង្ហាញពីសារៈសំខាន់នៃការផ្លាស់ប្តូរជលសាស្ត្រទឹកទន្លេដោយលក្ខណៈធម្មជាតិ ក្នុងរយៈពេលមួយឆ្នាំ ឬច្រើនឆ្នាំ ដើម្បីរក្សាឲ្យបាននូវភាពចម្រុះដ៏ច្រើនសន្ធឹកសន្ធាប់របស់ត្រី ។

គេប៉ាន់ស្មានថា ប្រហែល ៧០ ភាគរយ នៃបរិមាណត្រីដែលនេសាទបានទាំងអស់ ពឹងផ្អែកយ៉ាងខ្លាំងទៅលើហ្វូងត្រីដែលធ្វើបំលាស់ទី។ ពពួកត្រីទាំងនេះ ស្ថិតក្រោមការគំរាមកំហែងពីទំនប់ទាំងឡាយដែលគេគ្រោងនឹងសាង់សង់។ ការធ្លាក់ចុះយ៉ាងខ្លាំងនៃផលនេសាទ អាចបណ្តាលឲ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់សេដ្ឋកិច្ច និងសង្គម។

វារីវប្បកម្មកាន់តែមានលក្ខណៈសំខាន់ទៅៗ ទោះបីជាការនេសាទនៅតែផ្តល់បរិមាណត្រីច្រើនបំផុតនៃបរិមាណត្រីដែលទទួលបានក្នុងអាងទន្លេនេះក៏ដោយ។ ការលូតលាស់នៃការធ្វើវារីវប្បកម្មនាពេលថ្មីៗនេះ មានលក្ខណៈអស្ចារ្យណាស់ ដោយផលិតកម្មសរុបក្នុងឆ្នាំ ២០០៨ មានប្រហាក់ប្រហែល ១.៩ លានតោន គឺច្រើនជាង ៥ ដង នៃផលិតកម្មសរុបក្នុងឆ្នាំ ២០០០។ ក្នុងនោះប្រហែល ១.៦ លានតោន មានប្រភពពីដីសណ្តទន្លេមេគង្គ។ ត្រីចិញ្ចឹមបានត្រួតត្រាការលក់ដូរតាមបណ្តាទីផ្សារក្នុងទីក្រុងក្នុងប្រទេសថៃ និងឡាវ។ ការកើនឡើងនេះ គឺដោយសារការចិញ្ចឹមត្រីទីឡាផ្លា ត្រីប្រា និងបង្គា។ ក្នុងប្រទេសវៀតណាម ផលិតកម្មសរុបក្នុងឆ្នាំ ២០០៨ ឈានដល់ ១.៩ លានតោន គឺច្រើនជាង ៥ ដង នៃផលិតកម្មសរុបក្នុងឆ្នាំ ២០០០។ ការនាំចេញផលិតផលវារីវប្បកម្ម មានចំនួនប្រហែល ១ លានតោន ក្នុងមួយឆ្នាំៗ។

**ផលិតកម្មត្រីមកពីតំបន់ដីសណ្តប្រទេសវៀតណាម មិនរាប់បញ្ចូលការនេសាទខ្នាតតូចទេ**











# ទឹក និងតំបន់ដីសើមមានសភាពល្អប្រសើរ

សុខភាពរបស់ទឹកទន្លេ អាស្រ័យនឹងកត្តាមួយចំនួនដូចជា គុណភាពទឹក លំហូរទឹកទន្លេ និងបរិស្ថានតាមដងទន្លេ។ ការឡើងចុះរៀងរាល់ឆ្នាំនៃទឹកទន្លេមេគង្គ គឺជាអ្នកជំរុញដ៏សំខាន់ នាំទៅរកផលិតភាពខ្ពស់នៃទន្លេ និងតំបន់ដីសើមដែលពាក់ព័ន្ធជាមួយវា ហើយបង្កើតជាជម្រក និងចំណីអាហារដ៏សមស្របសម្រាប់ពពួករុក្ខជាតិ និងសត្វដ៏ច្រើនសន្ធឹកសន្ធាប់។ ខណៈដែលការអភិវឌ្ឍក្នុងតំបន់អាងទន្លេមេគង្គមានការកើនឡើង ការត្រួតពិនិត្យបន្តទៀតមានលក្ខណៈចាំបាច់ណាស់ក្នុងការលាតត្រដាងពីផលប៉ះពាល់នានាទៅលើគុណភាពទឹក ប្រព័ន្ធជីវៈចម្រុះក្នុងតំបន់ និងដែនជម្រកដីសើមរបស់វា។

## គុណភាពទឹក

ការត្រួតពិនិត្យជាប្រចាំចាប់ពីឆ្នាំ ១៩៨៥ បានបង្ហាញថា ជាទូទៅទឹកទន្លេមេគង្គមានគុណភាពល្អ លើកលែងតែតំបន់មួយចំនួនដែលនៅក្បែរទីក្រុង ឬតំបន់ដែលមានកសិកម្មអតិផល ឬវារីវប្បកម្ម។ កំហាប់សារធាតុចិញ្ចឹមនៅគ្រប់ស្ថានីយត្រួតពិនិត្យទាំងអស់ មានកម្រិតទាប លើកលែងតែស្ថានីយមួយចំនួនក្នុងតំបន់ដីសណ្តទន្លេមេគង្គដែលជាតំបន់កសិកម្មអតិផល។ និន្នាការនៃកម្រិតផូស្វ័រ និងនីត្រូសែនក្នុងតំបន់ដីសណ្ត បានបង្ហាញពីការធ្វើឲ្យខូចគុណភាពទឹក។ កំហាប់អាម៉ូញ៉ូមនៅតាមដងទន្លេមេគង្គ ស្ថិតនៅក្រោមកម្រិតបទដ្ឋានជាតិ ប៉ុន្តែវាបានកើនឡើងយ៉ាងខ្លាំង ក្នុងចន្លោះឆ្នាំ ២០០០-២០០៨ ដោយកំហាប់ខ្ពស់ៗត្រូវបានគេរកឃើញនៅក្នុងផ្នែកខាងលើនៃអាងទន្លេនេះក្បែរកន្លែងប្រសព្វគ្នាជាមួយដៃទន្លេផ្សេងៗក្នុងប្រទេសឡាវ និងនៅក្នុងទន្លេបាសាក់នៃប្រទេសកម្ពុជា។

គុណភាពទឹកនៅស្ទើរតែគ្រប់ស្ថានីយត្រួតពិនិត្យទាំងអស់ មានកម្រិត ″ល្អប្រសើរ″ សម្រាប់ការការពារជីវិតក្នុងទឹក ក្នុងចន្លោះឆ្នាំ ២០០០-២០០៨ ។ ទោះបីជាយ៉ាងណាក៏ដោយ ស្ថានភាពនេះមានការប្រែប្រួលនៅតាមដៃទន្លេមួយចំនួនដែលគុណភាពទឹកមានកម្រិត ″មធ្យម″ ដែលមានន័យថា ប្រភេទជីវៈមានជីវិតមួយចំនួនអាចស្ថិតក្រោមការគំរាមកំហែង ឬមានការថយចុះ។ នេះបង្ហាញពីផលប៉ះពាល់នៃការអភិវឌ្ឍវិស័យកសិកម្ម ការប្រើប្រាស់ដី និងនគរូបនីយកម្ម។

ខណៈពេលដែលការត្រួតពិនិត្យគុណភាពទឹកបានបង្ហាញពីស្ថានភាពនៃបរិស្ថានដែលសារពាង្គកាយក្នុងទឹករស់នៅ វាមិនបានវាយតម្លៃដោយផ្ទាល់ទៅលើស្ថានភាពសុខភាពរបស់សារពាង្គកាយទាំងនោះឡើយ។ ការត្រួតពិនិត្យជីវៈ ដែលជាការត្រួតពិនិត្យសុខភាពរបស់ក្រុមសារពាង្គកាយសំខាន់ៗ បានផ្តល់





ជាខ្នាតមួយផ្សេងទៀតសម្រាប់វាស់វែងទៅលើលក្ខខណ្ឌអេកូឡូស៊ីរបស់ទន្លេ។ ការត្រួតពិនិត្យជីវៈ រយៈពេលលើសពី ៥ ឆ្នាំ ក្នុងទីតាំងចំនួន ៥០ ក្នុងបរិស្ថានជាច្រើន បានបង្ហាញថា ទន្លេធំៗជាច្រើននៃអាងទន្លេមេគង្គក្រោមមិនទទួលរងការបំផ្លិចបំផ្លាញធ្ងន់ធ្ងរពីការអភិវឌ្ឍធនធានទឹក ឬការបោះចោលកាកសំណល់នោះទេ ទោះបីជាតំបន់ខ្លះបានបង្ហាញពីសញ្ញានៃការបំផ្លិចបំផ្លាញធ្ងន់ធ្ងរនេះក៏ដោយ។

ការសិក្សាថ្មីៗនេះក្នុងតំបន់ដីសណ្តទន្លេមេគង្គ បានបង្ហាញពីវត្តមាននៃសារធាតុបំពុល សរីរាង្គមិនបំបែកធាតុនៅក្នុងកករបាតទន្លេ និងសារពាង្គកាយក្នុងទឹក (ប្លង់តុងរុក្ខជាតិ ត្រី និងវារីសត្វដែលមានសម្បករឹង មានដូចជា បង្កង កំពឹស បង្គា ក្តាមជាដើម) ដោយក្នុងនោះមាន ដេ ដេ តេ ជាសារធាតុពុលដ៏សំខាន់។

កម្រិតខ្ពស់នៃលោហៈត្រូវបានជួបប្រទះក្នុងតំបន់ដែលមានចរាចរណ៍ទូកទៅមកច្រើន និង ឬដង់ស៊ីតេប្រជាជនខ្ពស់ ដែលភាគច្រើនស្ថិតនៅផ្នែកខាងក្រោមរាជធានីភ្នំពេញ និងក្នុងតំបន់ដីសណ្តទន្លេមេគង្គ។

ការអភិវឌ្ឍឧស្សាហកម្មក្នុងតំបន់អាងទន្លេមេគង្គក្រោម គឺនៅតែស្ថិតក្នុងដំណាក់កាលដំបូងនៅឡើយទេ ទោះបីការអភិវឌ្ឍនេះមានការកើនឡើងលឿនក៏ដោយ។ តាមការរំពឹងទុក តម្រូវការទឹកសម្រាប់ការប្រើប្រាស់ក្នុងឧស្សាហកម្ម គឺនឹងមានការកើនឡើងយ៉ាងខ្លាំងក្នុងបណ្តាប្រទេសទាំងអស់ក្នុងអាងទន្លេមេគង្គក្រោម ជាពិសេសក្នុងប្រទេសឡាវ និងកម្ពុជា នាប៉ុន្មានទសវត្សខាងមុខនេះ។

ការបំពុលទឹកដោយសារឧស្សាហកម្ម បានកើតមានឡើងក្នុងតំបន់អាងទន្លេមេគង្គក្រោម ជាពិសេសក្នុងរដ្ឋធានីវៀងចន្ទន៍ និងរាជធានីភ្នំពេញ ហើយជាទូទៅមានកាន់តែច្រើនក្នុងប្រទេសថៃភាគឦសាន និងតំបន់ដីសណ្តទន្លេមេគង្គ។ ជាទូទៅ ការសំអាតទឹកសំអុយចេញពីឧស្សាហកម្មនៅមានកម្រិតនៅឡើយ ហើយការដោះស្រាយ និងការបំបាត់ចោលកាកសំណល់ឧស្សាហកម្មដ៏មានគ្រោះថ្នាក់ មានលក្ខណៈមិនគ្រប់គ្រាន់ឡើយ។ មកទល់នឹងពេលនេះ ការបំពុលទឹកដោយសារឧស្សាហកម្ម គឺប្រមូលផ្តុំច្រើននៅជុំវិញបណ្តារោងចក្រ និងផ្នែកខាងក្រោមនៃតំបន់ទីប្រជុំជនធំៗ។ នារយៈពេលប៉ុន្មានឆ្នាំខាងមុខ បញ្ហានេះនឹងកើនឡើងនៅពេលដែលវិស័យឧស្សាហកម្មមានការរីកចម្រើន។







# តំបន់ដីសើម

តំបន់ដីសើម បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងដំណើរជីវិតរបស់ប្រជាជនរស់នៅក្នុងអាងទន្លេនេះ និងនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមក្នុងតំបន់។ ទន្លេនិងដៃរបស់វា ទឹកទំនប់ បឹង និងវាលភក់ល្បាប់ ជួយទ្រទ្រង់ដល់ប្រព័ន្ធអេកូឡូស៊ីជាច្រើន ដូចជា ទីទឹកជម្រៅរបស់ទន្លេ តំបន់វាលត្រែង និងតំបន់ព្រៃកោងកាង។

ការសិក្សាថ្មីៗនេះបានបង្ហាញថា ប្រជាជនជនបទបានប្រើប្រាស់យ៉ាងច្រើនសន្ធឹកសន្ធាប់នូវប្រភេទសារពាង្គកាយមានជីវិត ដែលពួកគេចាប់បាន ឬប្រមូលបានពីតំបន់ដីសើម។ ក្នុងមួយរដូវនៅក្នុងប្រព័ន្ធអេកូឡូស៊ីដែលពឹងផ្អែកលើដំណាំស្រូវក្នុងប្រទេសកម្ពុជា ចិន ឡាវ និងវៀតណាម ពពួកសារពាង្គទាំងនេះរួមមាន ត្រីចំនួន ១៤៥ ប្រភេទ សត្តវន្តជាតិ(សត្វក្នុងទឹកមានសម្បករឹង ដូចជា បង្កង បង្គា កំពឹស ក្តាម...)ចំនួន ១១ ប្រភេទ សិប្បីសត្វចំនួន ១៥ ប្រភេទ ល្មូនចំនួន ១៣ ប្រភេទ មណ្ឌុកសត្វ(សត្វរស់នៅក្នុងទឹកក៏បាន លើគោកក៏បាន មានដូចជា កង្កែប ហ៊ឹង គីង្គក់...) ចំនួន ១១ ប្រភេទ សត្វល្អិតចំនួន ១១ ប្រភេទ និងរុក្ខជាតិចំនួន ៣៧ ប្រភេទ។ ពពួកសារពាង្គកាយទាំងនេះត្រូវបានប្រមូលចេញពីដែនជម្រកលិចទឹកអចិន្ត្រៃយ៍ និងជម្រកលិចទឹកតាមរដូវ ដែលរួមមាន ទន្លេ បឹង ត្រពាំង វាលភក់ និងព្រៃលិចទឹក។ ក្រៅពីការប្រើប្រាស់ដោយផ្ទាល់ដើម្បីដាំដុះស្រូវ និងនេសាទត្រីទឹកសាប តំបន់ដីសើមក៏ត្រូវបានប្រើប្រាស់ដោយប្រយោលផងដែរ ដោយមិនមានភាពច្បាស់លាស់ តែយ៉ាងហោចណាស់ក៏វាមានសារៈសំខាន់ផងដែរ។ តំបន់ដីសើមធម្មជាតិអាចស្រូបយកទឹកជំនន់ដែលអាចបង្កគ្រោះថ្នាក់បាន ក្នុងរដូវវស្សា។ ឧទាហរណ៍ បឹងទន្លេសាបរបស់ប្រទេសកម្ពុជាបានពង្រីកទំហំផ្ទៃបឹងរហូតដល់ ៤ ទៅ ៥ ដង ក្នុងអំឡុងរដូវវស្សា។ បើមិនមានការស្រូបយកទឹកជំនន់ដោយធម្មជាតិនោះទេ រាជធានីភ្នំពេញអាចនឹងត្រូវលិចទឹកជារៀងរាល់ឆ្នាំ។



ទីក្រុងធំៗជាច្រើនក្នុងអាងទន្លេនេះ រួមមានទីក្រុង វៀងចន្ទន៍ និងភ្នំពេញ បានបង្ហូរទឹកសំអុយពីទីក្រុងរបស់ពួកគេចូលទៅក្នុងតំបន់ដីសើមធម្មជាតិធំៗ ហើយជាលទ្ធផល ពួកវាបានសំអាតទឹកក្នុងកម្រិតមួយដ៏ខ្ពស់ មុនពេលដែលទឹកកាកសំណល់ទាំងនោះហូរចូលទៅក្នុងទន្លេ។

ដោយសារតែតំបន់ដីសើមស្ថិតនៅក្នុងតំបន់ចន្លោះកណ្តាល ដែលជាតំបន់ប្រព័ន្ធអេកូឡូស៊ី ទឹកផ្លាស់ប្តូរបន្តិចម្តងៗទៅជាតំបន់ប្រព័ន្ធអេកូឡូស៊ីគោក ភាពខុសគ្នាតែបន្តិចបន្តួចនៅក្នុងបរិមាណពេលវេលា ឬរយៈពេលនៃលំហូរទឹកអាចធ្វើឲ្យមានការផ្លាស់ប្តូរយ៉ាងខ្លាំងដល់ធម្មជាតិរបស់តំបន់ដីសើម រុក្ខជាតិ សត្វ និងដំណើរការរបស់វា។





# ជីវៈចម្រុះដ៏សម្បូរបែប

អាងទន្លេមេគង្គ គឺជាតំបន់មួយក្នុងចំណោមតំបន់ជីវៈចម្រុះដ៏សម្បូរបែបបំផុតនៅក្នុងពិភពលោក ហើយក៏ជាតំបន់មួយក្នុងចំណោមតំបន់ដែលទទួលរងការគំរាមកំហែងខ្លាំងបំផុតផងដែរ។ ប្រព័ន្ធជីវៈចម្រុះនៃតំបន់ដីសើម និងតំបន់ព្រៃក្នុងអាងទន្លេមេគង្គ បានផ្តល់ជាជម្រកផ្សេងៗជាច្រើនដល់ពពួករុក្ខជាតិ និងសត្វដ៏គួរឲ្យភ្ញាក់ផ្អើល។ ការប៉ាន់ស្មានថ្មីៗនេះទៅលើជីវៈបរិស្ថាន ក្នុងតំបន់ទន្លេមេគង្គទាំងមូល មានរុក្ខជាតិចំនួន ២០,០០០ ប្រភេទ ថនិកសត្វចំនួន ៤៣០ ប្រភេទ បក្សីចំនួន ១,២០០ ប្រភេទ ល្មូននិងមណ្ឌុកសត្វចំនួន ៨០០ ប្រភេទ និងត្រីចំនួន ១,៣០០ ប្រភេទ ដោយមានប្រភេទថ្មីៗទៀតជាច្រើនកំពុងតែត្រូវបានសិក្សាលំអិត។ ទោះបីជាយ៉ាងណាក៏ដោយ ការអភិវឌ្ឍសេដ្ឋកិច្ចដែលមានសន្ទុះយ៉ាងលឿន កំណើនប្រជាជន និងតម្រូវការប្រើប្រាស់ដែលមានការកើនឡើងជាលំដាប់ បានដាក់សម្ពាធទៅលើបរិស្ថាន។ សត្វរស់នៅក្នុងអាងទន្លេមេគង្គចំនួន ១៤ ប្រភេទ ត្រូវបានចុះបញ្ជីជាប្រភេទសត្វរងគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរ (រួមមាន ត្រីផ្សោត) ២១ ប្រភេទ ត្រូវបានចុះបញ្ជីជាប្រភេទសត្វរងគ្រោះថ្នាក់ និង២៩ ប្រភេទ ផ្សេងទៀតកំពុងស្ថិតក្នុងស្ថានភាពងាយរងគ្រោះ។

ជម្រកសំខាន់ៗជាច្រើនរបស់បក្សី ត្រូវបានទទួលរងការខូចខាតដោយសារការស្រោះទឹក (អស់ទឹក)នៃតំបន់ដីសើម ការស៊ីស្មៅច្រើនហួសប្រមាណដោយគោក្របី ការទាញយកដីមមោកយកមកប្រើប្រាស់ ការកសាងអាងស្តុកទឹក ការប្រើប្រាស់ថ្នាំពុលកសិកម្ម និងការផ្លាស់ប្តូររបៀបធ្វើកសិកម្ម។ ក្រៅពីការបែងចែក និងការបំផ្លាញទីជម្រក បក្សីត្រូវទទួលរងការគំរាមកំហែងពីការប្រមូលពង ការប្រមាញ់ និងការជួញដូរ។

ប្រភេទត្រីក្នុងទន្លេមេគង្គ មានលើសពី ១,៣០០ ប្រភេទ ក្នុងនោះត្រីចំនួន ៧៤០ ប្រភេទ ជាត្រីមានប្រភពដើមក្នុងតំបន់នេះ។ ចំនួនត្រីធំៗកំពុងមានការធ្លាក់ចុះ ដែលក្នុងនោះរួមមានត្រីរាជ *(Pangasianodon gidas)* ដែលជាប្រភេទត្រីទំហំធំទទួលរងគ្រោះថ្នាក់ខ្លាំងផងដែរ។ ការគំរាមកំហែងទៅលើប្រភេទត្រី បំលាស់ទីដែលមានទំហំធំៗក្នុងទន្លេមេគង្គ រួមមានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដូចជាទំនប់ដែលផ្លាស់ប្តូរលំហូរទឹកទន្លេ និងបិទផ្លូវបំលាស់ទីរបស់ត្រី។ ដោយមិនមានសមត្ថភាពក្នុងការផ្លាស់ទីទៅកាន់ផ្នែកខាងលើ ឬខាងក្រោមរបស់ទន្លេ ហ្វូងត្រីមានឱកាសតិចតួចក្នុងការបង្កាត់ពូជ។

វាលទំនាបទន្លេមេគង្គក្រោម នៅតែមានតំបន់ជម្រកដ៏សុខសាន្តមួយចំនួនសម្រាប់ពពួកបក្សីទឹក ដោយមានបណ្តុំព្រៃឈើទាលខ្ពស់ៗ តំបន់ដីសើមនិងវាលស្មៅលិចទឹកតាមរដូវ និងដែនជម្រកតាមដងទន្លេ។ បឹងទន្លេសាបមានសារៈសំខាន់ណាស់សម្រាប់ពពួកបក្សីទឹកជាច្រើន ហើយនៅក្នុងឆ្នាំ ២០០៦ រដ្ឋាភិបាលកម្ពុជាបានដកហូតតំបន់វាលស្មៅលើសពី ២៥៨ គីឡូម៉ែត្រក្រឡា ដើម្បីការពារដែនជម្រកទាំងនេះពីការផ្លាស់ប្តូរទៅជាតំបន់ដាំដុះស្រូវ។

ទោះបីជាទន្លេមេគង្គ និងដៃរបស់វានៅតែអាចផ្តល់ជាឧទាហរណ៍មួយចំនួនក្នុងចំណោមឧទាហរណ៍ដែលនៅសេសសល់តិចតួចនៃហ្វូងបក្សី និងដែនជម្រកតាមដងទន្លេដែលមិនទាន់រងការបំផ្លាញនៅអាស៊ីអាគ្នេយ៍ក៏ដោយ ក៏ដែនជម្រកបក្សីក្នុងតំបន់ដីសើមកំពុងត្រូវបានប្រើប្រាស់ច្រើនឡើងៗ សម្រាប់ការតាំងទីលំនៅរបស់មនុស្សដែលតែងតែនាំយកមកជាមួយនូវចរាចរណ៍ទូកប្រើម៉ាស៊ីន។ តំបន់ដីសើម និងវាលស្មៅក្នុងតំបន់ដីសណ្តទន្លេមេគង្គ ក៏ទទួលរងការគំរាមកំហែងពីការធ្វើប្រពលវប្បកម្មវិស័យកសិកម្មជាទ្រង់ទ្រាយធំផងដែរ។

អាងទន្លេមេគង្គ គឺជាជម្រកសម្រាប់ពពួកល្មូន និងមណ្ឌុកសត្វមួយចំនួនដែលមានលក្ខណៈអស្ចារ្យ និងទទួលរងការគំរាមកំហែងបំផុតក្នុងពិភពលោក ប៉ុន្តែចំនួនប្រជាករជាច្រើនរបស់ពួកវាត្រូវបានបំផ្លាញដោយសារការបរបាញ់ និងការជួញដូរ។ ពពួកអណ្តើកទឹក ឬពាក់កណ្តាលទឹក ពស់ និងបង្កួយជាច្រើនត្រូវបានបរបាញ់សម្រាប់ធ្វើជាម្ហូប ឬលក់ដើម្បីទិញម្ហូប ឬថ្នាំពេទ្យនៅតាមទីផ្សារ ក្នុងស្រុក។ ប្រភេទល្មូនមានចំនួនច្រើនជាងគេបំផុតក្នុងចំណោមប្រភេទសត្វដែលគេជួញដូរក្នុងប្រទេសវៀតណាម ហើយការប្រមូលយកប្រភេទសត្វទាំងនេះ ត្រូវបានគេមើលឃើញថាមិនមាននិរន្តរភាព និងជាការគំរាមកំហែងដល់ជីវិតប្រភេទសត្វមួយចំនួន។



# ទន្លេភ្ជាប់ទំនាក់ទំនងពាណិជ្ជកម្ម និងការដឹកជញ្ជូន

អស់រយៈពេលរាប់ពាន់ឆ្នាំមកហើយ ទន្លេមេគង្គគឺជាផ្លូវធ្វើដំណើរដ៏សំខាន់មួយសម្រាប់ប្រជាជន និងការដឹកទំនិញរវាងទីប្រជុំជននានាតាមដងទន្លេនេះ។ បច្ចុប្បន្ន ទន្លេនេះកំពុងតែក្លាយជាផ្លូវភ្ជាប់ទំនាក់ទំនងយ៉ាងសំខាន់នៅក្នុងពាណិជ្ជកម្មអន្តរជាតិ និងកាន់តែមានប្រជាប្រិយភាពក្នុងវិស័យទេសចរណ៍។ នៅពេលដែលមានការដឹកជញ្ជូនទំនិញបរិមាណច្រើនក្នុងចំងាយផ្លូវដ៏ឆ្ងាយនោះ ការដឹកជញ្ជូនតាមផ្លូវទឹក គឺជាជម្រើសមួយដែលមានតម្លៃថោកជាង និងមានប្រសិទ្ធិភាពជាងការដឹកជញ្ជូនតាមផ្លូវថ្នល់ ហើយវាក៏ជួយដល់បរិស្ថានផងដែរ។

ថ្វីបើមានការលំបាកបណ្តាលមកពីការប្រែប្រួលកម្ពស់ទឹកតាមរដូវកាល (រៀងរាល់ឆ្នាំ កម្ពស់ទឹកក្នុងអាងទន្លេមេគង្គលើ អាចខុសគ្នា លើសពី ១៥ ម៉ែត្រ) និងផ្នែកនានារបស់ទន្លេមានជម្រៅរាក់ និងមានកម្លាំងទឹកហូរខ្លាំងក៏ដោយ ទំនិញដែលមានទម្ងន់លើសពី ៣០០,០០០ តោន ត្រូវបានដឹកជញ្ជូនតាមទន្លេមេគង្គ ចន្លោះទីក្រុងគុនមីង (Kunming) ប្រទេសចិន និងទីក្រុងបាងកក ប្រទេសថៃ ជារៀងរាល់ឆ្នាំ។ ទំហំពាណិជ្ជកម្មដោយនាវាចរណ៍ក្នុងតំបន់នេះ បានកើនឡើងទ្វេដង ក្នុងរយៈពេលបួនឆ្នាំ គិតដល់ឆ្នាំ ២០០៨។

ក្នុងកិច្ចខិតខំប្រឹងប្រែងក្នុងការកែលំអសុវត្ថិភាពចរាចរណ៍តាមដងទន្លេនេះ គន្លងសម្រាប់ការធ្វើនាវាចរណ៍ត្រូវបានវាស់វែង និងដាក់សញ្ញាសម្គាល់ដោយប្រើប្រាស់ឧបករណ៍ទំនើបៗ។ បច្ចុប្បន្ននេះ ការបំភ្លឺផ្លូវសម្រាប់ទូកដឹកទំនិញតាមដងទន្លេមេគង្គពីរាជធានីភ្នំពេញទៅដល់តំបន់ដីសណ្ត អាចឲ្យមានការធ្វើនាវាចរណ៍បានរយៈពេល ២៤ ម៉ោង។ ក្រៅពីមានជំនួយផ្នែកខាងក្រៅដល់ការធ្វើនាវាចរណ៍ ការពង្រីកទន្លេមេគង្គនាពេលបច្ចុប្បន្ននេះ គឺមានលក្ខណៈដូចគ្នាជាមួយនឹងទន្លេអន្តរជាតិផ្សេងៗទៀត ដោយមានការផ្តល់ប្រព័ន្ធព័ត៌មានដ៏ទំនើប ដូចជា តារាងនាវាចរណ៍អេឡិចត្រូនិច និងប្រព័ន្ធធ្វើអត្តសញ្ញាណកម្មដោយស្វ័យប្រវត្តិ ដើម្បីជួយសម្រួលដល់សុវត្ថិភាព និងប្រសិទ្ធិភាពនៃការធ្វើនាវាចរណ៍។

កិច្ចព្រមព្រៀងឆ្លងកាត់ព្រំដែនដោយស្របច្បាប់សម្រាប់សេរីភាពនៃការធ្វើនាវាចរណ៍ បានជួយផ្តល់ជាការគាំទ្រក្នុងការធ្វើនាវាចរណ៍ជាលក្ខណៈអន្តរជាតិនៅក្នុងតំបន់នេះ។ ដើម្បីបញ្ចប់រឿងរ៉ាវនេះ គណៈកម្មការទន្លេមេគង្គបានធ្វើការជាមួយប្រទេសកម្ពុជា និងវៀតណាម ដើម្បីបង្កើតកិច្ចព្រមព្រៀងមួយស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក ដែលជាការអភិវឌ្ឍដ៏សំខាន់នៅក្នុងទំនាក់ទំនងសេដ្ឋកិច្ចទ្វេភាគី ដែលកិច្ចព្រមព្រៀងនេះត្រូវបានចុះហត្ថលេខានៅក្នុងខែធ្នូ ឆ្នាំ ២០០៩។





ទស្សនៈអវិជ្ជមានដ៏ធ្ងន់ធ្ងរនៃកំណើននាវាចរណ៍ គឺស្ថានភាពនៃការបំពុលមានការកើនឡើង ដោយសារកំណើនយ៉ាងច្រើននៃនាវាធំៗដែលប្រើប្រាស់ប្រេងម៉ាស៊ូត។ ទោះបីជាពាណិជ្ជកម្ម នៃផលិតផលប្រេង ឧស្ម័ន និងសាំង រវាងប្រទេសវៀតណាម និងកម្ពុជាមានការកើនឡើងយ៉ាងខ្លាំងក៏ដោយ ក៏វិធានការការពារបរិស្ថានតិចតួចប៉ុណ្ណោះ បានលេចជារូបរាងឡើង ដើម្បីធានាដល់ការគ្រប់គ្រងទំនិញដ៏មានគ្រោះថ្នាក់ទាំងនេះឲ្យបានត្រឹមត្រូវ។ ការរក្សាទុកប្រេង និងឧស្ម័នក្នុងកំពង់ផែតាមដងទន្លេក្នុងប្រទេសកម្ពុជា និងវៀតណាម គឺជាបញ្ហាមួយដ៏គួរឲ្យបារម្ភ ដោយសារតែកន្លែងរក្សាទុកភាគច្រើនខ្វះខាតគម្រោងដោះស្រាយបញ្ហាដែលអាចកើតឡើងជាយថាហេតុ ឬធនធាន និងឧបករណ៍គ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹងភាពអាសន្ននៃការកំពប់ប្រេងឡើយ។ ការវិនិយោគបន្ថែមទៀតមានលក្ខណៈចាំបាច់ ដើម្បីផ្តល់ជាធនធានក្នុងការទប់ស្កាត់ និងឆ្លើយតបទៅនឹងការបំពុលដោយការកំពប់ប្រេង ដើម្បីរក្សាកំពង់ផែក្នុងស្រុក និងដើម្បីធានាដល់សកម្មភាពគោរពច្បាប់ និងសកម្មភាពត្រួតពិនិត្យត្រូវបានអនុវត្តក្នុងកម្រិតតំបន់ និងកម្រិតក្នុងស្រុក។

ការអភិវឌ្ឍថាមពលវារីអគ្គិសនីនៅតាមដងទន្លេ អាចបង្កើនកម្ពស់ទឹកនៅរដូវប្រាំង ដែលនឹងជួយជំរុញសមត្ថភាពធ្វើនាវាចរណ៍ និងផលប្រយោជន៍សេដ្ឋកិច្ចប្រកបដោយប្រសិទ្ធិភាព។

វិស័យទេសចរណ៍កំពុងតែមានការកើនឡើងនៅតាមដងទន្លេមេគង្គ។ អ្នកទេសចរ ចន្លោះពី ២០,០០០ ដល់ ២៥,០០០ នាក់ បានធ្វើដំណើរតាមដងទន្លេមេគង្គលើ (អ្នកទេសចរភាគច្រើន បានធ្វើដំណើរចន្លោះពី ហ៊ើយសៃ (Houei Sai) និងលួងព្រះបាង)។ ទន្លេមេគង្គក្រោម គឺជាគោលដៅទេសចរណ៍ដែលងាយធ្វើដំណើរឆ្លងកាត់ និងមានប្រជាប្រិយភាពជាងទន្លេមេគង្គលើ។ ប្រទេសកម្ពុជាមានអ្នកទេសចរចំនួន ៧១,៨៨៩ នាក់ មកលេងតាមផ្លូវទឹកក្នុងឆ្នាំ ២០០៨ ខណៈដែលនៅក្នុងឆ្នាំដដែលនោះ ប្រទេសវៀតណាមមានអ្នកទេសចរចំនួន ១៥៧,១៩៨ នាក់ មកលេងតាមទូក។

**តំលៃប្រែប្រួលនៃរបៀបផ្សេងៗនៃការដឹកជញ្ជូន ក្នុងអាង ទន្លេមេគង្គ។**




| | Distance (Km) | US$ per TEU[1] | US$ per 1000 TEU-Km |
|---|---|---|---|
| IWT | 530 | 155.44 | 293.06 |
| Rail | 435 | 175.51 | 403.48 |
| Road | 251 | 106.17 | 422.97 |

[1]TEU = 20-foot equivalent unit





# បញ្ហាប្រឈមនានានៅពេលអនាគត

ប្រព័ន្ធទន្លេមេគង្គ នឹងប្រឈមមុខនឹងបញ្ហាបរិស្ថានធំៗជាច្រើន នាប៉ុន្មានទសវត្សខាងមុខនេះ។ ការអភិវឌ្ឍថាមពលវារីអគ្គិសនី ការរីករាលដាលនៃការស្រោចស្រព និងការដឹកជញ្ជូនតាមផ្លូវទឹករួមជាមួយនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ នឹងផ្តល់ផលវិបាកធ្ងន់ធ្ងរដល់បរិស្ថានទន្លេនេះ ហើយក្នុងករណីខ្លះ វាអាចគំរាមកំហែងដល់ជីវៈចម្រុះនៃប្រព័ន្ធទឹកក្នុងអាងទន្លេនេះ និងដល់ជីវភាពប្រជាជនដែលរស់នៅពឹងផ្អែកទៅលើវា។

បណ្តារដ្ឋាភិបាលទាំងអស់នៃអាងទន្លេមេគង្គប្រាថ្នាចង់អភិវឌ្ឍធនធានទឹកទាំងនេះសម្រាប់ការស្រោចស្រព ថាមពលវារីអគ្គិសនី និងបម្រើបម្រាស់ផ្សេងៗ ដើម្បីជាផលប្រយោជន៍ដល់ប្រជាជនរាប់លាននាក់ដែលរស់នៅក្នុងភាពក្រីក្រនៅតាមតំបន់ជនបទ។ ស្របពេលជាមួយគ្នានោះដែរ រដ្ឋាភិបាលយល់ថា តម្រូវការក្នុងការអភិវឌ្ឍធនធានទឹក និងការសម្រេចបាននូវផលប្រយោជន៍សម្រាប់ប្រជាជនជនបទ ត្រូវតែមានលក្ខណៈដូចគ្នាជាមួយនឹងតម្រូវការរស់នៅរបស់ប្រជាកសិករ ដែលបន្ថែមទៅការដាំដុះរបស់ពួកគាត់តាមរយៈការនេសាទ និងការប្រមូលអាហារនិងវត្ថុផ្សេងៗពីក្នុងព្រៃ និងតំបន់ដីសើម។

## ថាមពលវារីអគ្គិសនី

ទន្លេមេគង្គ បានក្លាយជាតំបន់មួយក្នុងចំណោមតំបន់សកម្មបំផុតសម្រាប់ការអភិវឌ្ឍថាមពលវារីអគ្គិសនីក្នុងពិភពលោក។ ក្នុងអាងទន្លេមេគង្គផ្នែកខាងលើ ប្រទេសចិនកំពុងអនុវត្តគម្រោងចំនួន ៨ ដែលនឹងផ្លាស់ប្តូរយ៉ាងខ្លាំងដល់លំហូរទឹក ចាប់ពីរដូវវស្សារហូតដល់រដូវប្រាំង។ ក្នុងទន្លេមេគង្គក្រោម ទំនប់ថ្មីៗជាច្រើនត្រូវបានគេធ្វើគម្រោងសាងសង់តាមដងទន្លេ និងដៃរបស់វា។ តាមការប៉ាន់ស្មាន សក្តានុពលថាមពលវារីអគ្គិសនីនៃទន្លេមេគង្គក្រោមមាន ៣០,០០០ មេហ្គាវ៉ាត់ ក្នុងនោះប្រហែល ១០ ភាគរយ ត្រូវបាន

**សមត្ថភាពផ្តល់ថាមពលរបស់គម្រោងថាមពលវារីអគ្គិសនីដែលមានស្រាប់ កំពុងសាងសង់ និងមានគម្រោងសាងសង់/ត្រូវបានស្នើសុំដើម្បីសាងសង់ នៅក្នុងអាងទន្លេមេគង្គ**

| | សមត្ថភាពផ្តល់ថាមពល (គិតជាមេហ្គាវ៉ាត់) | | | |
|---|---|---|---|---|
| ប្រទេស | មានស្រាប់ | កំពុងសាងសង់ | មានគម្រោង / បានស្នើសុំសាងសង់ | សរុប |
| កម្ពុជា | ១ | — | ៥៥៨៩ | ៥៥៩០ |
| ឡាវ | ៦៦២ | ២៥៥៨ | ១៧.៦៨៦ | ២០,៩០៦ |
| ថៃ | ៧៤៥ | — | — | ៧៤៥ |
| វៀតណាម | ១២០៤ | ១០១៦ | ២៩៩ | ២៥១៩ |
| សរុប | ២៦១២ | ៣៥៧៤ | ២៣,៥៧៤ | ២៩,៧៦០ |





សាងសង់រួចរាល់ ដែលសំណង់ទាំងអស់ស្ថិតនៅតាមដៃទន្លេមេគង្គ។ ក្នុងចំណោមគម្រោងសរុបចំនួន ១២៤ នៃគម្រោង ដែលមានស្រាប់ កំពុងសាងសង់ និងគម្រោងតាមដៃទន្លេដ៏មានសក្តានុពលដែលមាននៅក្នុងប្រព័ន្ធទិន្នន័យ ថាមពលវារីអគ្គិសនីរបស់គណៈកម្មការទន្លេមេគង្គឆ្នាំ ២០០៩ គម្រោងច្រើនជាង ៧០ ភាគរយនៃគម្រោងទាំងអស់ ស្ថិតក្នុងប្រទេសឡាវ ហើយ ១០ ភាគរយទៀតស្ថិតក្នុងប្រទេសកម្ពុជា។ សំណើសុំរបស់ផ្នែកឯកជនសម្រាប់ការសាងសង់ទំនប់វារីអគ្គិសនីមានយ៉ាងតិចបំផុត ១១ គម្រោងនៅតាមដងទន្លេមេគង្គក្រោម។

ល្បឿនដ៏លឿននៃការអភិវឌ្ឍថាមពលវារីអគ្គិសនី បានទាក់ទាញចំណាប់អារម្មណ៍ស្តីពីសារៈសំខាន់នៃការវាយតម្លៃទៅលើកំណើននៃផលប៉ះពាល់របស់ទំនប់នានាតាមដៃទន្លេ ក្នុងនោះរួមមាន របបទឹកហូររបស់ដៃទន្លេ ផ្លូវបំលាស់ទីរបស់ត្រី គុណភាពទឹក និងលំហូរដីល្បាប់។ ផលប៉ះពាល់ទាំងនេះនឹងមានសភាពកាន់តែធ្ងន់ធ្ងរទៅៗ នៅពេលដែលចំនួននៃគម្រោងសាងសង់ទំនប់បន្តកើនឡើងនាពេលអនាគត។

ផលប៉ះពាល់ធ្ងន់ធ្ងរនៃការអភិវឌ្ឍថាមពលវារីអគ្គិសនី គឺជាការកើនឡើងនៃលំហូរទឹករដូវប្រាំង ដោយសារតែទឹកត្រូវបានស្តុកទុកក្នុងរដូវទឹកជំនន់ដើម្បីបង្កើតអគ្គិសនីនៅក្នុងខែបន្តបន្ទាប់ទៀត។ ការថយចុះនៃលំហូរទឹករដូវទឹកជំនន់មានចំនួនតិចតួចបំផុត។ វាមិនមែនគ្រាន់តែរបាយ និងបរិមាណនៃលំហូរទឹកតាមរដូវមានសារៈសំខាន់នោះទេ។ ពេលវេលានៃការចាប់ផ្តើមរបស់រដូវផ្សេងៗមានការប្រែប្រួលតិចតួច ពីមួយឆ្នាំទៅមួយឆ្នាំ ដូចនេះការប្រែប្រួលតិចតួចអាចមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់បរិស្ថាន។

ផលប៉ះពាល់រយៈពេលយូរមួយផ្សេងទៀតនៃទំនប់ គឺការទាក់យកដីល្បាប់។ ទន្លេមេគង្គ បាននាំយកមកនូវដីល្បាប់ដ៏មានជីជាតិក្នុងបរិមាណដ៏ច្រើនសន្ធឹកសន្ធាប់ ដែលមានសារៈសំខាន់សម្រាប់ផលិតភាពដ៏ខ្ពស់របស់តំបន់ដីសើម ដូចជា បឹងទន្លេសាប និងដីសណ្តទន្លេមេគង្គ។ ដូចនេះ ការធ្លាក់ចុះយ៉ាងសម្បើមនៃដីល្បាប់របស់ទន្លេ គឺជាកង្វល់មួយដ៏ធំ។ ប្រហែលពាក់កណ្តាលនៃការនាំដីល្បាប់មកកាន់អាងទន្លេមេគង្គក្រោម មានប្រភពពីអាងទន្លេមេគង្គលើ។ តាមការប៉ាន់ស្មាន បានឲ្យដឹងថា តំបន់ទឹកធ្លាក់យន់ណាម (Yunnan) ដែលត្រូវសាងសង់ក្នុងប្រទេសចិន នឹងទាក់យកដីល្បាប់ចំនួន ៩០ ភាគរយ។ ទំនប់ផ្សេងៗទៀតដែលគ្រោងនឹងសាងសង់តាមដងទន្លេមេគង្គ ក្នុងប្រទេសឡាវ រួមទាំងទំនប់តាមដៃទន្លេភាគខាងក្រោម នឹងបន្ថែមទៅលើផលប៉ះពាល់នេះ។

ស្របពេលដែលការសាងសង់ទំនប់ បានផ្តល់ឱកាសដល់ការកែលម្អសមត្ថភាពធ្វើនាវាចរណ៍តាមដងទន្លេដោយការផ្តល់នូវជម្រៅទឹកសមស្រប និងមិនប្រែប្រួល ទំនប់ទាំងនេះក៏អាចបណ្តាលឲ្យមានការគំរាមកំហែងដល់ការដឹកជញ្ជូនចំងាយឆ្ងាយ និងឆ្លងកាត់ព្រំដែនតាមដងទន្លេមេគង្គ។ ជាមួយគ្នានោះដែរ ឧបសគ្គទាំងអស់ដូចជា ទំនប់បានរារាំងការបង្កបង្កើតកូន និងបំលាស់ទីរបស់ត្រី។






# ការរៀបចំទុកជាមុនចំពោះផលប៉ះពាល់នៃអាកាសធាតុប្រែប្រួល

អាងទន្លេមេគង្គក្រោម ត្រូវបានរំពឹងថាជាតំបន់មួយក្នុងចំណោមតំបន់ដែលរងផលប៉ះពាល់យ៉ាងខ្លាំងដោយសារការប្រែប្រួលអាកាសធាតុ។ ក្រុមប្រឹក្សាអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (Intergovernmental Panel of Climate Change) បានបញ្ជាក់ថា សីតុណ្ហភាពទឹកភ្លៀងប្រចាំឆ្នាំ និងការហូរច្រោះ នឹងមានការកើនឡើង ហើយកម្ពស់ទឹកសមុទ្រ នឹងឡើងខ្ពស់ ដែលអាចប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់តំបន់ដីសណ្តទន្លេមេគង្គ។

ការប្រែប្រួលសីតុណ្ហភាព និងទឹកភ្លៀង អាចបណ្តាលឲ្យលំហូរទឹកទន្លេមេគង្គមានការកើនឡើងយ៉ាងខ្លាំង ទាំងក្នុងរដូវប្រាំង និងក្នុងរដូវវស្សា។ ការកើនឡើងនៃលំហូរទឹក អាចបង្កើនលទ្ធភាពប្រើប្រាស់ទឹកក្នុងរដូវប្រាំង ដើម្បីជាផលប្រយោជន៍ដល់វិស័យកសិកម្ម ប៉ុន្តែវាក៏បង្កើនភាពប្រថុយប្រថាននៃទឹកជំនន់ផងដែរក្នុងរដូវវស្សា។ តំបន់ទាបៗនៅភាគខាងក្រោមនៃខេត្តក្រចេះ និងនៅក្នុងតំបន់ដីសណ្តទន្លេមេគង្គ អាចស្ថិតក្នុងគ្រោះថ្នាក់យ៉ាងខ្លាំង។ ទិដ្ឋភាពទូទៅ បានលាក់កំបាំងនៃលក្ខណៈខុសប្លែកគ្នាយ៉ាងខ្លាំងនៅទូទាំងអាងទន្លេនេះ។

ក្នុងតំបន់ដីសណ្តទន្លេមេគង្គ ការកើនឡើងកម្ពស់ទឹកសមុទ្រត្រូវបានរំពឹងទុកជាកត្តាសំខាន់បំផុតទាក់ទងនឹងទឹកជំនន់ ។ តាមការប៉ាន់ស្មានបានបង្ហាញថា ប្រហែល ៣០ ភាគរយ នៃតំបន់ដីសណ្តទន្លេមេគង្គក្នុងប្រទេសវៀតណាម នឹងត្រូវលិចទឹក ប្រសិនបើកម្ពស់ទឹកសមុទ្រកើនឡើងមួយម៉ែត្រ នៅឆ្នាំ ២១០០ ។

តាមការរំពឹងទុក ការកើនឡើងកំដៅផែនដី នឹងផ្លាស់ប្តូរតំបន់ភូមិសាស្ត្ររបស់ប្រភេទសារពាង្គកាយមានជីវិតទៅកាន់តំបន់ភាគខាងជើង ឬរយៈកម្ពស់ខ្ពស់ៗនៅតាមតំបន់ភ្នំ ដោយសារតែប្រភេទសារពាង្គកាយនីមួយៗត្រូវបានសម្របខ្លួនទៅនឹងកម្រិតសីតុណ្ហភាពច្បាស់លាស់មួយ។ ប្រភេទសារពាង្គកាយមានជីវិតមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយការឡើងចុះតាមរដូវរបស់ទឹកទន្លេ។ ដូចនេះ របៀបនៃលំហូរទឹកតាមរដូវដែលមានការប្រែប្រួល អាចជះឥទ្ធិពលយ៉ាងខ្លាំង ដល់ការរស់នៅរបស់សារពាង្គកាយនាពេលអនាគត និងផលិតភាពនៃប្រព័ន្ធអេកូឡូស៊ី។

ការរួមផ្សំគ្នារវាងសីតុណ្ហភាពកើនឡើង និងទឹកភ្លៀងថយចុះនៅក្នុងតំបន់មួយចំនួននៃអាងទន្លេមេគង្គក្រោម អាចបណ្តាលឲ្យការហូរច្រោះមានការថយចុះ ហើយកម្ពស់ទឹកក្រោមដីកាន់តែទាបទៅៗ ដែលធ្វើឲ្យតំបន់ដីសើមមួយចំនួនរួញតូច រីឯផ្នែកខ្លះទៀតរបស់អាងទន្លេនេះ ដែលទទួលទឹកភ្លៀងច្រើនជាងមុន អាចមានការផ្លាស់ប្តូរទៅជាប្រភេទតំបន់ដីសើមកាន់តែច្រើន។

ការគិតគូរពិចារណាអំពីរបៀបក្នុងការសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ ទាមទារឲ្យមានការពិចារណាទៅលើកត្តាជំរុញផ្សេងៗទៀតទៅលើការផ្លាស់ប្តូរក្នុងអាងទន្លេមេគង្គក្រោម។ ផែនការអភិវឌ្ឍអាងទន្លេមេគង្គក្រោម ត្រូវបានបង្កើតឡើងសម្រាប់តំបន់នេះ ដោយផ្អែកលើគម្រោងអភិវឌ្ឍរបស់បណ្តាប្រទេសទាំងបួនតាមដងទន្លេនេះ។ ឧទាហរណ៍ គម្រោងអភិវឌ្ឍមួយ ដែលមានការអភិវឌ្ឍថាមពលវារីអគ្គិសនី និងការស្រោចស្រពសម្រាប់រយៈពេល ២០ ឆ្នាំ ខាងមុខ ដែលត្រូវរួមបញ្ចូលជាមួយផែនការមួយក្នុងចំណោមផែនការនានា ទាក់ទងនឹងការផ្លាស់ប្តូរអាកាសធាតុរបស់ IPCC បានបង្ហាញថា ផលប៉ះពាល់មួយចំនួននៃការផ្លាស់ប្តូរអាកាសធាតុទៅលើលំហូរទឹក អាចនឹងត្រូវទូទាត់សងវិញ តាមរយៈការអភិវឌ្ឍដែលត្រូវគ្រោងទុក។ មូលហេតុចម្បងសម្រាប់រឿងនេះ គឺសមត្ថភាពស្តុកទឹករបស់ទំនប់វារីអគ្គិសនី និងទំនប់ស្រោចស្រព។





# ផលប៉ះពាល់ និងការគ្រប់គ្រងទឹកជំនន់

អាកាសធាតុមូសុងត្រូពិចនៃអាងទន្លេមេគង្គក្រោម គឺមានលក្ខណៈភ្លៀងធ្លាក់ច្រើនតាមរដូវកាល ដែលនាំឲ្យមានទឹកជំនន់ប្រចាំឆ្នាំ និងមានរដូវពីរដាច់ដោយឡែកពីគ្នា ពោលគឺរដូវទឹកជំនន់ និងរដូវលំហូរទឹកតិច។ ទោះបីជាទឹកជំនន់ធំៗអាចបង្កជាមហន្តរាយធ្ងន់ធ្ងរ ប៉ុន្តែទឹកជំនន់ធម្មតានាំមកនូវផលប្រយោជន៍ដ៏សម្បើម។

ការខូចខាតជាមធ្យមរបស់ទឹកជំនន់ធ្ងន់ធ្ងរ នៅក្នុងអាងទន្លេមេគង្គក្រោម គឺប្រមាណជា ៦០-៧០ លានដុល្លារ ក្នុងមួយឆ្នាំ ចំណែកឯតម្លៃនៃផលប្រយោជន៍ប្រចាំឆ្នាំនៃឆ្នាំដែលមានទឹកជំនន់ធម្មតា ត្រូវប៉ាន់ប្រមាណថាមានតម្លៃ ៨-១០កោដិដុល្លារ ពោលគឺច្រើនជាង ១០០ ដង។ កិច្ចការដែលត្រូវធ្វើ គឺដើម្បីកាត់បន្ថយការខូចខាត និងឥទ្ធិពលអវិជ្ជមានរបស់ទឹកជំនន់ ខណៈពេលដែលកំពុងរក្សាឲ្យបាននូវផលប្រយោជន៍របស់វា។

ក្នុងឆ្នាំ ២០០៨ ទឹកជំនន់តាមដងទន្លេមេគង្គ និងដៃរបស់វាដែលបង្កដោយព្យុះត្រូពិចធ្ងន់ធ្ងរ បានកើតឡើងតាមដងទន្លេផ្នែកខាងលើនៃទន្លេមេគង្គនៅក្នុងប្រទេសឡាវ និងថៃ។ ភាពធ្ងន់ធ្ងររបស់ទឹកជំនន់តាមដងទន្លេនេះ បានថយចុះបន្តិចម្តងៗនៅផ្នែកខាងក្រោមនៃទីក្រុងវៀងចន្ទន៍។ ទឹកជំនន់មានលក្ខណៈប្រក្រតីនៅពេលឆ្លងកាត់តំបន់វាលទំនាបប្រទេសកម្ពុជា និងដីសណ្តទន្លេមេគង្គ។ ទឹកជំនន់កើតឡើងភ្លាមៗចំនួនតិចតួច បានកើតឡើងក្នុងប្រទេសកម្ពុជា និងវៀតណាម។

ការគ្រប់គ្រងគ្រោះថ្នាក់ដែលបង្កដោយទឹកជំនន់ មានការជាប់ទាក់ទងនឹងគំនិតផ្តួចផ្តើមក្នុងតំបន់ផ្សេងៗគ្នាជាច្រើន ដើម្បីបង្កើននូវភាពឆាប់ស្តារឡើងវិញរបស់សហគមន៍ដែលអាចទទួលរងទឹកជំនន់ ដូចនេះពួកគេអាចរស់នៅបានល្អប្រសើរជាងមុនជាមួយនឹងទឹកជំនន់ ហើយអាចទទួលបាននូវអត្ថប្រយោជន៍នៃការជន់លិច។

ការខូចខាតភាគច្រើនដែលបង្កដោយទឹកជំនន់តាមដងទន្លេមេគង្គ គឺប្រមូលផ្តុំច្រើនក្នុងប្រទេសវៀតណាម និងកម្ពុជាដែលជាកន្លែងដែលទឹកជំនន់បានបង្កការខូចខាតអស់រាប់រយលានដុល្លារ ដោយការខូចខាតផលិតផលស្រូវ។ កំណើនប្រជាជន និងភាពមានដីជាតិរបស់វាលទំនាបលិចទឹក មានន័យថា ប្រជាជនកាន់តែច្រើនឡើងៗ នឹងប្រឈមមុខនឹងគ្រោះថ្នាក់ទឹកជំនន់ ពិសេសក្នុងប្រទេសកម្ពុជា និងតំបន់ដីសណ្តក្នុងប្រទេសវៀតណាម។ ទោះបីជាយ៉ាងណាក៏ដោយ ការកំណត់តំបន់ប្រើប្រាស់ដី អាចកាត់បន្ថយគ្រោះថ្នាក់បង្កដោយទឹកជំនន់ក្នុងកម្រិតសហគមន៍ និងជួយក្នុងការអភិរក្សតំបន់ដីសើម ខណៈពេលដែលផែនទីតំបន់គ្រោះថ្នាក់ បង្កដោយទឹកជំនន់ដែលត្រូវបានប្រើប្រាស់សម្រាប់ការកំណត់តំបន់នេះ មានសារៈសំខាន់ណាស់ក្នុងការធ្វើផែនការដើម្បីចាត់វិធានការដោះស្រាយនៅពេលមានអាសន្នទឹកជំនន់។

ការការពារទឹកជំនន់ (ការគ្រប់គ្រងសំណង់ និងការអភិវឌ្ឍ) អាចកាត់បន្ថយ ប៉ុន្តែមិនអាចបំបាត់ចោលនូវផលប៉ះពាល់នានារបស់ទឹកជំនន់ទៅលើសំណង់ និងហេដ្ឋារចនាសម្ព័ន្ធបានទេ។ ការលើកភូមិឲ្យខ្ពស់ ដូចដែលបានធ្វើនៅតំបន់ដីសណ្តប្រទេសវៀតណាម គឺជាវិធានការមួយដ៏មានប្រសិទ្ធិភាពក្នុងការគ្រប់គ្រងគ្រោះថ្នាក់បង្កដោយទឹកជំនន់ ដែលជាទូទៅ វាមានផលប៉ះពាល់តិចតួចទៅលើបរិស្ថាន។ វាបានផ្តល់ភាពធូរស្រាលពីផលប៉ះពាល់ភ្លាមៗរបស់ទឹកជំនន់ទៅលើសហគមន៍ ស្របពេលដែលរក្សាបាននូវផលប្រយោជន៍សេដ្ឋកិច្ច និងមានសក្តានុពលខ្ពស់ ក្នុងនាមជាវិធានការគ្រប់គ្រងគ្រោះថ្នាក់នាពេលអនាគតដែលមិនសូវទទួលបានការចាប់អារម្មណ៍។

វិធានការគ្រប់គ្រងគ្រោះថ្នាក់តាមរយៈសំណង់ ដែលជាវិធានការគ្រប់គ្រងទឹកដែលបានមកពីទឹកជំនន់ ដូចជា ទំនប់ទឹកជាដើម គឺមានឥទ្ធិពលតិចតួចទៅលើគ្រោះថ្នាក់ដែលបង្កដោយទឹកជំនន់ធំៗ ជាពិសេសនៅក្នុងប្រទេសកម្ពុជា និងដីសណ្តប្រទេសវៀតណាម។

វាលទំនាបលិចទឹកសំខាន់ៗនៅជុំវិញកន្លែងប្រសព្វគ្នារវាងទន្លេមេគង្គ និងដៃរបស់វា អាចទទួលរងនូវជំនន់ទឹក នឹងបានមកពីទឹកជំនន់ទន្លេមេគង្គ និងគួបផ្សំជាមួយការជន់លិចពីទឹកជំនន់របស់ទន្លេមេគង្គ និងដៃរបស់វាដែលជន់ក្នុងពេលដំណាលគ្នា។





**Mekong River Commission**

P.O. Box 6101, Unit 18, Ban Sithane Neua, Sikhottabong District, Vientiane, Lao PDR
Telephone (856) 21 263 263 • Facsimile (856) 21 263 264
E-mail: mrcs@mrcmekong.org • www.mrcmekong.org









